KB ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
Daehan Specialized Bank Plc.

# របាយការណ៍ ប្រចាំឆ្នាំ 2018



KDSB

មាគ៌ាហិរញ្ញវត្ថុដ៏ល្អសម្រាប់អនាគតរបស់លោកអ្នក

# មាតិកា

## ជំពូកទី1 : សេចក្តីផ្តើម


> សាររបស់នាយកប្រតិបត្តិ ..... 03
> ព័ត៌មានធនាគារ ..... 04
> ព័ត៌មានម្ចាស់ភាគហ៊ុន (KB Financial Group) ..... 05
> ព័ត៌មានម្ចាស់ភាគហ៊ុន (KB Kookmin Card) ..... 06
> ព័ត៌មានម្ចាស់ភាគហ៊ុន (Indochina Bank) ..... 07
> ចក្ខុវិស័យ និងបេសកកម្ម ..... 08
> រចនាសម្ព័ន្ធគ្រប់គ្រង ..... 09
> អភិបាលកិច្ចធនាគារ ..... 10


## ជំពូកទី2 : ចំណុចសំខាន់ៗក្នុងឆ្នាំ2018


> ចំណុចសំខាន់ៗផ្នែកហិរញ្ញវត្ថុឆ្នាំ2018 ..... 12
> សកម្មភាពទំនួលខុសត្រូវក្នុងសង្គមរបស់ធនាគារ ..... 13
> សកម្មភាពដទៃផ្សេងទៀត ..... 15


## ជំពូកទី3 : របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម


> របាយការណ៍ក្រុមប្រឹក្សាភិបាល ..... 20
> របាយការណ៍សវនករឯករាជ្យ ..... 23
> របាយការណ៍ហិរញ្ញវត្ថុ
. តារាងតុល្យការ ..... 26
. របាយការណ៍លទ្ធផល ..... 27
. របាយការណ៍បម្រែបម្រួលមូលធន ..... 28
. របាយការណ៍លំហូរសាច់ប្រាក់ ..... 29
. កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ ..... 30




# សារពីនាយកប្រតិបត្តិ

ខ្ញុំសូមជូនពរលោកអ្នកឲ្យមានជោគជ័យនៅគ្រប់ភារកិច្ចទាំងអស់។ ខ្ញុំមានមោទនភាពសូមរាយការណ៍ជូនអំពីសមទ្ធិផលរបស់ធនាគារក្នុងឆ្នាំ 2018 ដែលជារបាយការណ៍ប្រចាំឆ្នាំដំបូងនៅក្រោមឈ្មោះ **ធនាគារឯកទេស ខេប៊ី ដេហាន ម.ក**។
ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះអស់ពីដួងចិត្តចំពោះម្ចាស់ភាគហ៊ុនរបស់យើងសម្រាប់ការគាំទ្រ និងការជំរុញលើកទឹកចិត្តយ៉ាងខ្លាំងក្នុងការសម្រេចបាននូវសមិទ្ធិផលគួរឲ្យកត់សម្គាល់របស់ធនាគារ។

**ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** គឺជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន KB Financial Group ដែលជាក្រុមហ៊ុនហិរញ្ញវត្ថុលំដាប់កំពូលមួយនៅក្នុងប្រទេសកូរ៉េ ហើយក្រុមហ៊ុននេះបានរីកលូតលាស់ក្លាយជាក្រុមហ៊ុនឈានមុខគេមួយខាងនវានុវត្តន៍ និងសេវាកម្មនៅក្នុងគ្រប់ផ្នែកហិរញ្ញវត្ថុទាំងអស់ រួមទាំងធនាគារ មូលបត្រ និងប័ណ្ណឥណទានផងដែរ។ ពិសេសជាងនេះ បើទោះបីជាធនាគារបានប្រឡូកចូលក្នុងផ្នែកផ្តល់ប្រាក់កម្ចីទិញរថយន្តក្រោយគេបន្តិចក៏ពិតមែន ក៏ប៉ុន្តែទីផ្សារប្រទេសកូរ៉េមានការភ្ញាក់ផ្អើលជាខ្លាំងដោយសារកំណត់ត្រានៃការលក់បានច្រើនជាង 100 ពាន់លានវ៉ុនក្នុងមួយខែ។ ធនាគារមានកំណត់ត្រាកំណើនចំនួន7.5 ដងនៅក្នុងរយៈពេលពីរឆ្នាំបន្ទាប់ពីការហក់ចូលទៅក្នុងទីផ្សារ។ ការនេះ អាចសម្រេចទៅបាន ដោយសារការផ្តល់ជូននូវសេវាកម្មដែលមានលក្ខណៈឆាប់រហ័ស និងត្រឹមត្រូវពិតប្រាកដ។

នៅក្នុងប្រទេសឡាវ ក្រុមហ៊ុនភតិសន្យារថយន្តដែលមានឈ្មោះថា KB Kolao Leasing ត្រូវបានបង្កើតឡើងនៅក្នុងខែកុម្ភៈ ឆ្នាំ 2017 និងបានដំណើរការដោយជោគជ័យ។ យើងកំពុងកំណត់ពីបេសកកម្មរបស់យើង។ **ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** ចង់ក្លាយជាធនាគារដែលមានផ្តល់ជូននូវសេវាកម្មឆាប់រហ័ស និងបត់បែនជាងគេនៅក្នុងប្រទេសកម្ពុជា។ បន្ថែមលើនេះ បេសកកម្មរបស់យើង គឺដើម្បីធ្វើឲ្យប្រជាជនមានអារម្មណ៍សប្បាយចិត្តជាមួយនឹង **ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** ។ នៅពេលដែលអតិថិជនជួបជាមួយ **ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** ពួកគេមានអារម្មណ៍ត្រេកអរចំពោះអនាគតដ៏ភ្លឺស្វាងមួយ។ សម្រាប់ជាប្រយោជន៍អតិថិជនរបស់យើងក្នុងពេលអនាគត យើងផ្តល់ជូននូវសេវាកម្មឆាប់រហ័ស និងបត់បែន ប្រៀបដូចជារថយន្តទំនើបកំពុងបើកបរនៅលើមហាវិថីដែរ។ យើងដឹងថាហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយឲ្យអតិថិជនមានលទ្ធភាពអាចទិញទ្រព្យសកម្មបាន។

យើងនឹងខិតខំប្រឹងប្រែងឲ្យអស់ពីលទ្ធភាពក្នុងការផ្តល់ជូននូវអត្ថប្រយោជន៍ដ៏ល្អប្រសើរសម្រាប់ជីវិតរស់នៅ និងអាជីវកម្មរបស់អតិថិជនយើងនៅក្នុងប្រទេសកម្ពុជា ផ្អែកលើបទពិសោធន៍ និងចំណេះដឹងដែលទទួលបានពីប្រទេសកូរ៉េ និងប្រទេសឡាវ។
សូមបើកបរនៅលើ "**មាគ៌ាថ្មីក្នុងវិស័យហិរញ្ញវត្ថុ**" តាមរយៈ **ធនាគារឯកទេស ខេប៊ី ដេហាន ម.ក**!
សូមអរគុណ។

**នាយកប្រតិបត្តិ**

**គង់ សាងយ៉ុន**




**ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** គឺជាការវិនិយោគរួមគ្នារវាងក្រុមហ៊ុន KB Kookmin Card និងធនាគារ Indochina Bank ។ ក្រុមហ៊ុន KB Kookmin Card គឺជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន KB Financial Group។ ក្រុមហ៊ុន KB Financial Group គឺជាក្រុមហ៊ុនឈានមុខគេមួយដែលផ្តល់ជូននូវផលិតផលនិងសេវាកម្មហិរញ្ញវត្ថុជាច្រើនប្រភេទ ផ្សេងៗគ្នា ។ ក្រុមហ៊ុននេះជាសមាជិកនៃសន្ទស្សន៍វាយតម្លៃចីរភាពក្រុមហ៊ុន (Dow Jones Sustainability Indices) នៃទីផ្សារមូលបត្រ NYSE។ ធនាគារ Indochina Bank ធ្លាប់មានបទពិសោធន៍ជោគជ័យនៅក្នុងវិស័យហិរញ្ញវត្ថុទិញរថយន្តនៅប្រទេសឡាវកន្លងមក។ ហេតុនេះ **ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** គឺអាចផ្តល់ជូននូវសេវាកម្មដែលឆាប់រហ័ស និងមានភាពបត់បែនជូនដល់ទីផ្សារឥណទាននៅកម្ពុជា ដើម្បីបង្កើតសង្គមហិរញ្ញវត្ថុដែលមានភាពល្អប្រសើរជាងមុន។

# ព័ត៌មានធនាគារ

| | |
|---|---|
| ឈ្មោះធនាគារ | **ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** |
| ដើមទុនចុះបញ្ជី | 18,750,000 ដុល្លារអាមេរិក |
| ម្ចាស់ភាគហ៊ុន | ក្រុមហ៊ុន KB Koomin Card កាន់កាប់ 90%<br>ធនាគារ Indochina Bank កាន់កាប់ 10% |
| សាវតារ | - នៅខែសីហា ឆ្នាំ 2008 បានបង្កើតជា **ធនាគារឯកទេស តូម៉ាតូ** (Tomato Specialized Bank)<br>- ឆ្នាំ 2018 បានផ្លាស់ប្តូរមកជា **ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** (KB Daehan Specialized Bank Plc.) |
| វិស័យពាណិជ្ជកម្ម | ឯកទេសខាងផ្តល់កម្ចីទិញរថយន្ត និងកម្ចីទិញផ្ទះ |
| ចំនួនបុគ្គលិក | 101 នាក់ |
| សវនករ | PricewaterhouseCoopers (Cambodia) Ltd. |
| ការិយាល័យកណ្តាល | អគារលេខ 1 (វិមានការិយាល័យ អូវល) ជាន់ទី 21 និង 22 ផ្លូវ 360<br>សង្កាត់បឹងកេងកង 1 ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ប្រទេសកម្ពុជា។ |

# ព័ត៌មាន ម្ចាស់ភាគហ៊ុន

## ក្រុមហ៊ុន KB Financial Group

ក្រុមហ៊ុន KB Financial Group គឺជាក្រុមហ៊ុនឈានមុខគេមួយ ដែលផ្តល់នូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុជាច្រើនប្រភេទផ្សេងៗគ្នា។ ក្រុមហ៊ុននេះ គឺជាក្រុមហ៊ុនដែលមានការលូតលាស់លឿនជាងគេបំផុតគ្មានគូប្រៀប ដែលមានចំនួនអតិថិជនច្រើន មានបណ្តាញចែកចាយធំទូលាយ និងមានកេរ្តិ៍ឈ្មោះល្បីល្បាញ។



ក្រុមហ៊ុន KB Financial Group គឺជាស្ថាប័នហិរញ្ញវត្ថុលំដាប់ទី 1 របស់ប្រទេសកូរ៉េ និងកាន់កាប់លើក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន 12 រួមទាំងក្រុមហ៊ុន KB Kookmin Card ផងដែរ។







* *សន្ទស្សន៍ការពេញចិត្តរបស់អតិថិជនថ្នាក់ជាតិ (NCSI), មជ្ឈមណ្ឌលផលិតកម្មកូរ៉េ

ក្រុមហ៊ុន KB Financial Group មានបណ្តាញនៅក្រៅប្រទេស ដែលគ្របដណ្តប់លើទ្វីបទាំងអស់។ ក្រុមហ៊ុននេះមានគោលបំណងចង់ក្លាយជាស្ថាប័នហិរញ្ញវត្ថុសាលកឈានមុខគេមួយនៅក្នុងទីផ្សារហិរញ្ញវត្ថុអាស៊ីក្នុងនាមជាសមាជិកចុះបញ្ជីក្នុងទីផ្សារមូលបត្រ NYSE។




ចំណាំ)* គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2017

# ព័ត៌មានម្ចាស់ភាគហ៊ុន

## ក្រុមហ៊ុន KB Kookmin Card

ក្រុមហ៊ុន KB Kookmin Card គឺជាក្រុមហ៊ុនប័ណ្ណឥណទានលំដាប់កំពូលដែលមានអតិថិជនប្រមាណ 19.7លាននាក់ នៅក្នុងប្រទេសកូរ៉េ។ យើងចង់ក្លាយជា "ធនាគារផ្តល់ដំណោះស្រាយសម្រាប់បែបផែនរស់នៅលំដាប់ទី 1" ដែលផ្តល់ជូននូវផលិតផលហិរញ្ញវត្ថុដែលល្អជាងគេសម្រាប់អតិថិជន។ ដោយមានការដឹកនាំពីអ្នកដែលមានទេពកោសល្យលំដាប់ពិភពលោក និងមានការច្នៃប្រឌិតខ្ពស់ យើងសង្ឃឹមថាធនាគារនេះនឹងក្លាយជាដៃគូដែលលោកអ្នកទុកចិត្តបាន នៅក្នុងការសម្រេចឲ្យបាននៅជីវិតដែលមានភាពសប្បាយរីករាយ។



| | |
|---|---|
| កាលបរិច្ឆេទបង្កើត | កញ្ញា 1987 |
| វិស័យពាណិជ្ជកម្ម | ប័ណ្ណឥណទាន កម្ចីឥណទាន កម្ចីទិញរថយន្ត |
| និយោជិត | 1,562 នាក់ |
| អ្នកប្រើប័ណ្ណ | 19.7លាននាក់ (40% នៃប្រជាជនកូរ៉េ) |
| ពាណិជ្ជករ | 2.5លាននាក់ |
| ទំហំប្រតិបត្តិការសាច់ប្រាក់ | 116 ពាន់លានដុល្លារ /មួយឆ្នាំ |
| ទ្រព្យសកម្មសរុប | 16.5 ពាន់លានដុល្លារ |
| អត្ថប្រយោជន៍ប្រតិបត្តិការ | 351លានដុល្លារ |



## FitchRatings

### A-(ស្ថិតស្ថេរ)

ទទួលបានពិន្ទុ 'A-' និងគំនិត 'ស្ថិតស្ថេរ' ដែលជាចំណាត់ថ្នាក់ខ្ពស់បំផុតក្នុងចំណោមក្រុមហ៊ុនឯកទេសឥណទាននៅក្នុងប្រទេសកូរ៉េ (វិច្ឆិកា 2017)

## Moody's

### A2 (ស្ថិតស្ថេរ)

ទទួលបានពិន្ទុ 'A2' និងគំនិត 'ស្ថិតស្ថេរ' ដែលជាពិន្ទុឥណទានដំបូងរបស់ **KB Kookmin Card** ពី **Moody's** (មិថុនា 2019)



កម្ចីទិញរថយន្តថ្មី

ទ្រព្យសកម្មសរុប 1.15 ពាន់លានដុល្លារ

**លេខ 1**

ប័ណ្ណមូលប្បទានបត្រ M/S




ចំនួនទឹកប្រាក់ប្រើប្រាស់ 60 ពាន់លានដុល្លារ

**លេខ 1**

ការប្រើប្រាស់ប័ណ្ណ M/S



ចំនួនទឹកប្រាក់ប្រើប្រាស់ 116 ពាន់លានដុល្លារ

**លេខ 2**



# ព័ត៌មាន
# ម្ចាស់ភាគហ៊ុន

ធនាគារ Indochina Bank Ltd ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសឡាវ ក្នុងឆ្នាំ 2008។ ម្ចាស់ភាគហ៊ុនរបស់ធនាគារ រួមមាននីតិបុគ្គល និងរូបវន្តបុគ្គលដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញជាមួយ និងប្រវត្តិអាជីវកម្មដែលមានស្ថេរភាព និងរឹងមាំដូចជាលោក Oh Sei Young និងក្រុមហ៊ុន LVMC Investment Ltd.។ ធនាគារនេះ មានបណ្តាញសាខាចំនួន 13 កន្លែងនៅទូទាំងខេត្តទាំងអស់។ បទពិសោធន៍ និងចំណេះដឹងរបស់ធនាគារនឹងត្រូវចែករំលែកមកកាន់ **ធនាគារឯកទេស ខេប៊ី ដេហាន ម.ក**។






## ទីស្នាក់ការកណ្តាល

អសយដ្ឋានៈ អាគារ ខូឡាវ, 116, ផ្លូវសឹង្ហ 23,
ប្រអប់សំបុត្រលេខ 6029
ទូរស័ព្ទ (+856-21) 455 000-3
ទូរសារ (+856-21) 455 111

## ចក្ខុវិស័យរបស់ធនាគារ

“ ដើម្បីក្លាយខ្លួនជាធនាគារឯកជនទី1 នៅក្នុងប្រទេសឡាវ ក្នុងការរីកចម្រើនផ្នែកអាជីវកម្ម សេវាអតិថិជន ផលិតផល អត្ថប្រយោជន៍ និងការបង្កើតម៉ាកយីហោ និងបន្តលើកកម្ពស់សេវាកម្មរបស់យើងដើម្បីបំពេញតាមតម្រូវការរបស់អតិថិជនជាមួយនឹងកម្រិតនៃការពេញចិត្តខ្ពស់បំផុត។”

# ចក្ខុវិស័យ និងបេសកកម្ម

ចក្ខុវិស័យរបស់**ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** គឺដើម្បីក្លាយខ្លួនជាធនាគារឯកទេសដ៏ល្អផ្តាច់គេនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈបទពិសោធន៍ដ៏ជោគជ័យពីប្រទេសកូរ៉េ។

បេសកកម្មរបស់**ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** គឺដើម្បីធ្វើឲ្យពលរដ្ឋមានអារម្មណ៍សប្បាយរីករាយ តាមរយៈសេវាកម្មរហ័ស និងមានភាពបត់បែនដូចជាការបើកបររថយន្តនៅលើផងវិថីដែរ។




## ក្លាយជាធនាគារឯកទេសដ៏ល្អផ្តាច់គេនៅក្នុងប្រទេសកម្ពុជា

### ផលិតផល

> ផលិតផលថ្មី

- កម្ចីទិញរថយន្ត ជួល-ទិញរថយន្តមួយទឹក
- លក់ដុំ (ក្រុមហ៊ុននាំចូល)
- កម្ចីទិញផ្ទះ ផ្អែកតាមការវាយតម្លៃហានិភ័យ

### ដំណើរការ

> ប្រតិបត្តិការ

- បុគ្គលដែលមានប្តេជ្ញាចិត្តខ្ពស់
- ដំណើរការផ្តល់កម្ចីរហ័សទាន់ចិត្ត
- ពាក្យស្នើសុំកម្ចីតាមទូរស័ព្ទដៃ

> ព័ត៌មានទំនាក់អតិថិជន

- មជ្ឈមណ្ឌលសេវាអតិថិជន គេហទំព័រ

### កម្មវិធី

> កម្មវិធីដែលមានភាពស្មោះត្រង់

- ការរក្សាទុកអតិថិជនដែលមានស្រាប់
- ការផ្តល់ជូនអត្ថប្រយោជន៍នានា

> ដំណើរជីវិតរបស់អតិថិជន

- ការគ្រប់គ្រងវដ្តជីវិត
- ការលើកទឹកចិត្តការទិញសេវាជាថ្មី

# រចនាសម្ព័ន្ធអង្គភាព



# អភិបាលកិច្ច

## រចនាសម្ព័ន្ធ និងសមាសភាពក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់**ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** រួមមានសមាជិកបួនរូប ក្នុងនោះរួមមានអភិបាលឯករាជ្យម្នាក់ផងដែរ។ អភិបាលទាំងអស់ត្រូវបានតែងតាំងដោយមហាសន្និបាទរបស់ម្ចាស់ភាគហ៊ុន។ អភិបាលទាំងអស់ជាអ្នកជំនាញនៅក្នុងផ្នែករៀងៗខ្លួន ដែលមានបទពិសោធន៍ច្រើននៅក្នុងវិស័យនានា ដូចជាអាជីវកម្ម គ្រប់គ្រង និងច្បាប់ជាដើម។ ប្រធានក្រុមប្រឹក្សាភិបាលត្រូវបានបោះឆ្នោតជ្រើសរើសដោយសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់។

## ក្រុមប្រឹក្សាភិបាល

| | |
|---|---|
| លោក Kang Nam Che | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Kong Sang Yeon | អភិបាល |
| លោក Lee Jae Hoo | អភិបាល |
| លោក Kim Hyong Kun | អភិបាលឯករាជ្យ |

## គណៈកម្មការ

### . គណៈកម្មការសវនកម្ម

គណៈកម្មការសវនកម្ម ត្រូវបានបង្កើតឡើងតាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៅថ្ងៃទី20 ខែកក្កដា ឆ្នាំ2018 ដើម្បីជួយដល់ក្រុមប្រឹក្សាភិបាលក្នុងការអនុវត្តអភិបាលកិច្ច និងការត្រួតពិនិត្យលើទំនួលខុសត្រូវរបស់ខ្លួន។

គណៈកម្មការនេះ រួមមានសមាសភាពដូចជា៖

| | |
|---|---|
| លោក Kim Hyong Kun | ប្រធាន (អភិបាលឯករាជ្យ) |
| លោក Lee Sang In | សមាជិក |
| លោក ម៉ែន ណារិទ្ធ | សមាជិក |

### . គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ

គណៈកម្មការនេះ ត្រូវបង្កើតនូវប្រព័ន្ធវាយតម្លៃ និងផ្តល់សំណងដែលយុត្តិធម៌ ស្របទៅតាមការបំពេញការងាររបស់គណៈគ្រប់គ្រង និងបុគ្គលិក និងមជ្ឈដ្ឋាននៃការផ្តល់ប្រាក់រង្វាន់ជាទូទៅ។

| | |
|---|---|
| លោក Kim Hyong Kun | ប្រធាន (អភិបាលឯករាជ្យ) |
| លោក Kong Sang Yeon | សមាជិក |
| លោក Lee Sang In | សមាជិក |

### . គណៈកម្មការហានិភ័យ

គណៈកម្មការនេះ ដើរតួជាស្ថាប័នធ្វើសេចក្តីសម្រេចដែលមានអំណាចខ្ពស់ជាងគេបំផុត។ គណៈកម្មការនេះបង្កើត និងអនុម័តយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ និងគោលការណ៍ណែនាំដើម្បីកំណត់ វាស់វែង គ្រប់គ្រង តាមដាន និងបង្ការរាល់ហានិភ័យទាំងអស់ដែលកើតចេញពីប្រតិបត្តិការសាច់ប្រាក់នានារបស់ធនាគារឲ្យបានទាន់ពេលវេលា។

| | |
|---|---|
| លោក Kong Sang Yeon | ប្រធាន |
| លោក Lee Sang In | សមាជិក |
| លោក Park Jong Deok | សមាជិក |

KB ធនាគារឯកទេស ខេបី ដេហាន ម.ក
Daehan Specialized Bank Plc.

*Your New Highway in Finance*



# ចំណុចសំខាន់ៗក្នុងឆ្នាំ 2018

# ចំណុចសំខាន់ៗផ្នែកហិរញ្ញវត្ថុឆ្នាំ2018

**ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** បានផ្លាស់ប្ដូរជាធនាគារដ៏ខុសប្លែកទាំងស្រុងមួយ ដែលបានបញ្ចេញចំនួនតួលេខប្រាក់កម្ចីយ៉ាងច្រើនគួរឱ្យកត់សម្គាល់ និងបានបង្កើនទ្រព្យសកម្មសរុបលើសពីបួនដង។

## ទ្រព្យសកម្មសរុប




## ចំនួនប្រាក់កម្ចីដែលបានបញ្ចេញរួច




**410%**
កំណើនទ្រព្យសកម្មសរុប

**3,400%**
កំណើនប្រាក់កម្ចីប្រចាំខែដែលបានបញ្ចេញ

**ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** ក៏បានគ្រប់គ្រងហានិភ័យបានយ៉ាងល្អផងដែរ តាមរយៈចំណេះដឹងខ្ពស់ដែលទទួលបានក្នុងបទពិសោធន៍នៃការគ្រប់គ្រងហានិភ័យនៅក្នុងប្រទេសកូរ៉េ។ មានអនុបាតប្រាក់កម្ចីមិនដំណើរការស្មើនឹង 0.19%។ នៅក្នុងឆ្នាំ2018គឺជាឆ្នាំដំបូងដែលធនាគារបានប្រឡូកខ្លួនចូលក្នុងទីផ្សារដែលធនាគារបានវិនិយោគប្រាក់ក្នុងការចំណាយជាច្រើនប្រភេទ។ នេះគឺជាមូលហេតុដែលប្រាក់ចំណូលសុទ្ធទាបជាងឆ្នាំមុន។

## អនុបាតប្រាក់កម្ចីមិនដំណើរការ




**1,337%**
ការកាត់បន្ថយអនុបាតប្រាក់កម្ចីមិនដំណើរការ



## ចំណូលសុទ្ធ



# សកម្មភាពទំនួលខុសត្រូវសង្គមរបស់ធនាគារ

## ការបរិច្ចាគទៅឲ្យ Messiah Philharmonic Ensemble

Messiah Philharmonic Ensemble ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ2018 ដើម្បីជួយដល់សាលាអន្តរជាតិ Messiah និងសាលាតូរ្យតន្ត្រី Messiah និងដើម្បីជួយដល់វិទ្យាស្ថាននេះដើម្បីបន្តការអប់រំផ្នែកតូរ្យតន្ត្រី។ ធនាគារមានគោលបំណងក្នុងការផ្តល់នូវតន្ត្រីបែបក្លាសិកដែលល្អបំផុតជូនដល់សង្គមកម្ពុជា និងដើម្បីបង្កើតវប្បធម៌តន្ត្រីក្លាសិក និងការសម្តែងតន្ត្រីនេះ។ នៅក្នុងពិធីបើកសម្ពោធ **ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** បានបរិច្ចាគប្រាក់ដល់វិទ្យាស្ថាននេះ។










## ការដាំដើមកោងកាង

ការដាំដើមកោងកាងជួយការពារសង្គមកម្ពុជា។ ដើមកោងកាងជំរុញឲ្យមានបង្កង បង្គារ និងសត្វសមុទ្រច្រើនទៀត។ បុគ្គលិក **ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** បានដាំដើមកោងកាងនៅខេត្តកំពត។

# សកម្មភាពទទួលខុសត្រូវសង្គមរបស់ធនាគារ

## ការដំឡើងឧបករណ៍ចំណាំងផ្លាតនៅផ្លូវកែង

ទីក្រុងភ្នំពេញមានផ្លូវតូចៗជាច្រើន។ ផ្លូវទាំងនេះអាចមានគ្រោះថ្នាក់ចំពោះអ្នកបើកបរម៉ូតូ ឬរថយន្ត និងអ្នកថ្មើរជើង។ **ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** បានដំឡើងកញ្ចក់ចរាចរណ៍តាមកែងផ្លូវតូចៗ ដែលវាអាចជួយកាត់បន្ថយគ្រោះថ្នាក់បានមួយចំនួន។











## ការចែកប្រអប់កាដូដល់សិស្ស

នៅក្នុងខែសីហា ក្រុមហ៊ុន KB Kookmin Card ដែលជាម្ចាស់ភាគហ៊ុនរបស់**ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** បានផ្តល់ប្រអប់កាដូចំនួន1000 កាដូដល់កុមារនៅក្នុងខេត្តកំពង់ស្ពឺ។ ប្រអប់កាដូទាំងអស់នោះ រៀបចំដោយបុគ្គលិករបស់ក្រុមហ៊ុន KB Kookmin Card និងអតិថិជននៅក្នុងប្រទេសកូរ៉េ។ កាដូទាំងនោះ រួមមានសម្លៀកបំពាក់ ស្បែកជើង សៀវភៅ និងតុក្កតា។ **ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** មានផែនការបន្តសកម្មភាពនេះជាមួយពលរដ្ឋកូរ៉េជាបន្តបន្ទាប់ទៀត។

# សកម្មភាពដទៃ ផ្សេងទៀត






## ការចុះកិច្ចសន្យាពាណិជ្ជកម្ម

**ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** បានធ្វើលទ្ធកម្មពីធនាគារឯកទេស តូម៉ាតូ (Tomato Specialized Bank) ដែលជាធនាគារតូចមួយ ដែលគ្រប់គ្រងដោយ KDIC នៅក្នុងខែមេសា បន្ទាប់ពីទទួលបានការអនុញ្ញាតពី **ធនាគារជាតិនៃ កម្ពុជា** (NBC) ក្នុងខែមីនា ។

**ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** បានធ្វើការបន់ស្រន់សុំឲ្យសម្រេចការទិញក្រុមហ៊ុននេះនៅរមណីយដ្ឋានវត្តភ្នំផងដែរ ។ **ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** តែងតែគោរពប្រពៃណីវប្បធម៌ និងប្រជាជនកម្ពុជា ។



# សកម្មភាពដទៃផ្សេងទៀត





## ការផ្លាស់ប្តូរការិយាល័យ

**ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** បានផ្លាស់ប្តូរការិយាល័យពីវិថីសម្តេចប៉ាន (214) ដែលជាទីតាំងការិយាល័យ **ធនាគារឯកទេស តូម៉ាតូ** ទៅកាន់អគារថ្មីស្រឡាងមួយនៅវិមានការិយាល័យ អូវល។

ការិយាល័យថ្មីនេះគឺជាតំណាងនៃចក្ខុវិស័យរបស់ **ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** ដែលមានរូបរាងទ្រង់ទ្រាយខុសគ្នា និងកម្រិតនៃការរចនាផ្ទៃខាងក្នុងអគារក្នុងកម្រិតពិសេសបំផុត ដែលជានិមិត្តរូបនៃរលកថ្មីផ្នែកហិរញ្ញវត្ថុ។



## ពិធីជប់លៀងអបអរសាទរ

**ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** បានអញ្ជើញអ្នកផ្គត់ផ្គង់រថយន្ត និងអតិថិជនសំខាន់ៗ និងបុគ្គលិកធនាគារឲ្យចូលក្នុងការិយាល័យថ្មីរបស់ខ្លួន។

ធនាគារបានប្រកាសចក្ខុវិស័យថ្មីរបស់ខ្លួន។

# សកម្មភាពផ្សេងទៀត




## ពិធីបើកសម្ពោធជាផ្លូវការ

នៅថ្ងៃទី6 ខែកញ្ញា ឆ្នាំ2018 នៅសណ្ឋាគារ សុខាភ្នំពេញ **ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** បានបើកសម្ពោធធនាគារខ្លួនជាផ្លូវការ។ ភ្ញៀវកិត្តិយសសំខាន់ៗបានចូលរួម និងសាទរចំពោះការបើកធនាគារថ្មីនេះ។





# ការរៀបចំសិក្ខាសាលា

**ធនាគារឯកទេស ខេប៊ី ដេហាន ម.ក** បានទៅខេត្តកំពតដើម្បីរៀបចំសិក្ខាសាលានៅទីនោះ។សិក្ខាកាមផ្តោតជាសំខាន់លើការងារជាក្រុម និងការកសាងអនាគតដ៏ត្រចះត្រចង់មួយ។ ពួកគេបានចូលរួមក្នុងសកម្មភាពជាច្រើន។





ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
Daehan Specialized Bank Plc.

*Your New Highway in Finance*



# របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
# (អតីត ធនាគារ ឯកទេស តូម៉ាតូ)

# របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

# របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមដាក់បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ ធនាគារឯកទេស ខេបី ដេហាន ម.ក (អតីត ធនាគារឯកទេស តូម៉ាតូ) (ហៅកាត់ថា “ធនាគារ”) សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018។

## អំពីធនាគារ

ធនាគារបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី24 ខែមិថុនា ឆ្នាំ2008 ក្រោម វិញ្ញាបនបត្រចុះបញ្ជីលេខ Co.5029E/2008 ចេញដោយក្រសួងពាណិជ្ជកម្ម។ ធនាគារបានទទួលអាជ្ញាប័ណ្ណជាធនាគារឯកទេស ពីធនាគារជាតិ នៃ កម្ពុជា (ហៅកាត់ថា “ធនាគារកណ្តាល”) នៅថ្ងៃទី10 ខែកក្កដា ឆ្នាំ2008 ដើម្បីធ្វើប្រតិបត្តិការជាធនាគារឯកទេស។

នៅថ្ងៃទី22 ខែមីនា ឆ្នាំ2018 ធនាគារកណ្តាលបានអនុម័តឱ្យធនាគារប្តូរនាមករណ៍របស់ខ្លួនពី “ធនាគារឯកទេស តូម៉ាតូ” ទៅជា “ធនាគារ ឯកទេស ខេបី ដេហាន ម.ក”។

ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅជាន់ទី21 និង22 នៃអគារលេខ 1 ផ្លូវលេខ 360 សង្កាត់ បឹងកេងកង 1 ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ធនាគារ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី 31 ខែធ្នូ ឆ្នាំ2018 ត្រូវបានដាក់បង្ហាញនៅលើរបាយការណ៍លទ្ធផល ទំព័រទី27។

## ដើមទុន

ក្នុងអំឡុងឆ្នាំនេះ ធនាគារបានបង្កើនដើមទុនរបស់ខ្លួនពី 8,100,000 ដុល្លារអាមេរិក ដល់ 18,750,000 ដុល្លារអាមេរិកតាមរយៈការដាក់ដើមទុនបន្ថែមចំនួន 10,650,000 ដុល្លារអាមេរិក។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ គឺការផ្តល់កម្ចីទិញយានយន្ត និងកម្ចីទូទៅ ដល់សហគ្រាសធុនតូច និងមធ្យមដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ហ្វាស៊ីលីធីហិរញ្ញវត្ថុអាក្រក់ និងសង្ស័យ

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ពាក់ព័ន្ធទៅនឹងការជម្រះហ្វាស៊ីលីធីហិរញ្ញវត្ថុអាក្រក់ចេញពីបញ្ជី ឬការធ្វើសំវិធានធនហ្វាស៊ីលីធីហិរញ្ញវត្ថុអាក្រក់ និងសង្ស័យ ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់ហ្វាស៊ីលីធីហិរញ្ញវត្ថុអាក្រក់ទាំងអស់ដែលបានដឹង ត្រូវបានជម្រះចេញពីបញ្ជី និងបានកត់ត្រាសំវិធានធនពេញលេញ សម្រាប់ហ្វាស៊ីលីធីហិរញ្ញវត្ថុអាក្រក់ និងសង្ស័យ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមកម្រិតនៃការយល់ដឹង ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយដែលនាំឱ្យចំនួនហ្វាស៊ីលីធីហិរញ្ញវត្ថុអាក្រក់ដែលបានជម្រះចេញពីបញ្ជី ឬចំនួនសំវិធានធន ហ្វាស៊ីលីធីហិរញ្ញវត្ថុអាក្រក់ និងសង្ស័យ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានតម្លៃមិនគ្រប់គ្រាន់នោះទេ។

# ទ្រព្យសកម្ម

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា ទ្រព្យសកម្មទាំងឡាយត្រូវបានកត់ត្រាបន្ថយឱ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចទទួលស្គាល់បានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះនិងផ្អែកតាមកម្រិតនៃការយល់ដឹង ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយដែលអាចបណ្តាលឱ្យតម្លៃទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ពុំត្រឹមត្រូវជាសារវន្តនោះទេ។

## បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ៖

ក. មិនមានបន្ទុកណាមួយលើទ្រព្យសកម្មរបស់ធនាគារ ដែលបានកើតឡើងដោយសារការដាក់វាបញ្ចាំ សម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំមក និង

ខ. មិនមានបំណុលយថាភាពណាមួយរបស់ធនាគារ ដែលបានកើតឡើងចាប់តាំងពីដំណាច់ឆ្នាំមក ក្រៅពីបំណុលផ្សេងៗ នៅក្នុងដំណើរការអាជីវកម្មធម្មតានោះទេ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ក្រៅពីបំណុលយថាហេតុផ្សេងៗ ស្តីពីការមិនអនុលោមតាមប្បញ្ញត្តិរបស់ធនាគារកណ្តាល ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗរបស់ធនាគារ បានក្លាយជាការបង្ខំឱ្យសង ឬអាចនឹងត្រូវទាមទារឱ្យសងក្នុងរយៈពេល12ខែ បន្ទាប់ពីដំណាច់ឆ្នាំ ដែលនឹង ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃកំណត់សងនោះទេ។

## ការប្រែប្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានរៃកញែកនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចបណ្តាលឱ្យចំនួនទឹកប្រាក់ដែលបានដាក់បង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលប្រតិបត្តិការរបស់ធនាគារក្នុងឆ្នាំនេះ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយឡើយ។ តាមយោបល់របស់ក្រុមប្រឹក្សាភិបាល រវាងដំណាច់ឆ្នាំ រហូតមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមានខ្ទង់គណនី ប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ខុសប្រក្រតីណាមួយ ដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ ក្នុងឆ្នាំដែលរបាយការណ៍នេះត្រូវបានធ្វើឡើងនោះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការងារក្នុងអំឡុងឆ្នាំ និងរហូតមកដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម៖

### ក្រុមប្រឹក្សាភិបាល

| | |
|---|---|
| លោក Kang Nam Che | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Kong Sang Yeon | អភិបាល (អភិបាលប្រតិបត្តិ) |
| លោក Lee Jae Hoo | អភិបាល (អភិបាលមិនប្រតិបត្តិ) |
| លោក Kim Hyon Kun | អភិបាល (អភិបាលឯករាជ្យ) |

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើង និងបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ធនាគារ សម្រាប់ដំណាច់ឆ្នាំ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលត្រូវ ៖

1. អនុវត្តគោលការណ៍គណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះឱ្យស៊ីសង្វាក់គ្នា។
2. អនុវត្តតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មាន និងគោលការណ៍ណែនាំដែលចេញដោយធនាគារជាតិ នៃ កម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា ហើយប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញឱ្យមានភាពត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនោះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់ចំនួនទឹកប្រាក់ឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
3. រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។
4. រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែមានករណីសន្មតសមរម្យថាធនាគារនឹងមិនអាចបន្តកិច្ចប្រតិបត្តិការអាជីវកម្មនៅពេលអនាគតដ៏ខ្លី និង
5. គ្រប់គ្រង និងដឹកនាំធនាគារឱ្យមានប្រសិទ្ធភាព តាមរយៈការសម្រេចចិត្តជាសារវន្តទាំងអស់ដែលជះឥទ្ធិពលដល់ប្រតិបត្តិការ និងលទ្ធផលរបស់ធនាគារ ហើយត្រូវធានាថាផលប៉ះពាល់ទាំងនោះត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថាធនាគារបានអនុវត្តតាមតម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលបានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងកំណត់សម្គាល់ទាំងឡាយដែលភ្ជាប់មកជាមួយ ដែលបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ 2018 និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ធនាគារសម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា។

ចុះហត្ថលេខាដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។




**លោក គង់ សាខយ៉ុន**

**នាយកប្រតិបត្តិ**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី22 ខែមីនា ឆ្នាំ2019

# របាយការណ៍សវនករឯករាជ្យ

**ជូនភាគទុនិក ធនាគារឯកទេស ខេបី ដេហាន ម.ក**

## មតិយោបល់របស់យើងខ្ញុំ

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារឯកទេស ខេបី ដេហាន ម.ក(អតីត ធនាគារឯកទេស តូម៉ាតូ) (ហៅកាត់ថា "ធនាគារ") បង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ អំពីស្ថានភាព ហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ធនាគារ សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា។

## របាយការណ៍ដែលយើងខ្ញុំបានធ្វើសវនកម្ម

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ រួមមាន៖

- តារាងតុល្យការគិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2018
- របាយការណ៍លទ្ធផលសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍បម្រែបម្រួលមូលធនសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ និង
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ

### មូលដ្ឋាននៃមតិយោបល់របស់យើងខ្ញុំ

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា(ហៅកាត់ថា"ស្តង់ដារសវនកម្ម")។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលអនុលោមទៅតាមស្តង់ដារទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌ"ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ" នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល មានភាពគ្រប់គ្រាន់ និងសមហេតុផល ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

### ឯករាជ្យ

យើងខ្ញុំមានឯករាជ្យពីធនាគារ ដែលអនុលោមទៅតាមក្រមសីលធម៌សម្រាប់គណនេយ្យករវិជ្ជាជីវៈ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារក្រមសីលធម៌អន្តរជាតិ (ហៅកាត់ថា "ក្រមសីលធម៌អន្តរជាតិ") និងអនុលោមទៅតាមក្រមសីលធម៌របស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (ហៅកាត់ថា "ក្រមសីលធម៌ វគសក")។ យើងខ្ញុំបានបំពេញកាតព្វកិច្ចក្នុងការទទួលខុសត្រូវផ្នែកក្រមសីលធម៌ផ្សេងៗទៀត ដែលកំណត់ដោយ ក្រមសីលធម៌អន្តរជាតិ និង ក្រមសីលធម៌ វគសក។

### ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រងទទួលខុសត្រូវចំពោះព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលយើងខ្ញុំបានទទួលបាននាកាលបរិច្ឆេទរបាយការណ៍សវនកម្មនេះ រួមមាន របាយការណ៍ក្រុមប្រឹក្សាភិបាល និង ឧបសម្ព័ន្ធស្តីពីតម្រូវការនៃប្រកាសរបស់ធនាគារកណ្តាល ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំទេ។ មតិយោបល់របស់យើងខ្ញុំចំពោះរបាយការណ៍ហិរញ្ញវត្ថុពុំបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗនោះទេ ហើយយើងខ្ញុំមិនធ្វើការធានាអះអាងចំពោះព័ត៌មានទាំងនោះទេ។

ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ យើងខ្ញុំទទួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗ ដើម្បីពិចារណាថាតើព័ត៌មានផ្សេងៗទាំងនោះមានភាពផ្ទុយគ្នាជាសារវន្តពីរបាយការណ៍ហិរញ្ញវត្ថុ ឬផ្ទុយពីការយល់ដឹងរបស់យើងខ្ញុំផ្អែកលើលទ្ធផលនៃការធ្វើសវនកម្ម ឬមានការរាយការណ៍ពីកំហុសឆ្គងជាសារវន្តដែលបានកើតឡើងឬទេ។

ផ្អែកទៅលើការងារដែលយើងខ្ញុំបានបំពេញ ទៅលើព័ត៌មានផ្សេងៗដែលយើងខ្ញុំទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តដែលកើតចេញពីព័ត៌មានផ្សេងៗទាំងនេះយើងខ្ញុំត្រូវរាយការណ៍ពីអង្គហេតុនៃកំហុសឆ្គងទាំងនោះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ចំពោះបញ្ហានេះទេ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា និងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឱ្យចៀសផុតពីការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម ដោយប្រើមូលដ្ឋានគណនេយ្យសម្រាប់និរន្តរភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងគ្រោងនឹងបិទអាជីវកម្មរបស់ធនាគារ ឬបញ្ឈប់ប្រតិបត្តិការដោយមិនមានជម្រើសណាផ្សេងប្រកបដោយភាពប្រាកដប្រជាណាមួយ។

អ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច ត្រូវមានការទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

## ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺស្វែងរកអំណះអំណាងដែលសមហេតុផល ថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ និងចេញរបាយការណ៍សវនកម្មដែលមានមតិយោបល់របស់យើងខ្ញុំ។

ការអះអាងដែលសមហេតុផលគឺជាការអះអាងក្នុងកម្រិតខ្ពស់ ប៉ុន្តែវាមិនមែនជាការធានាថាសវនកម្មដែលបានធ្វើឡើងដោយអនុលោមទៅតាមស្តង់ដារសវនកម្ម តែងតែរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយវាត្រូវបានចាត់ទុកថាមានលក្ខណៈជាសារវន្ត ប្រសិនបើការរាយការណ៍ខុសនីមួយៗ ឬការរាយការណ៍ខុសសរុប អាចត្រូវបានរំពឹងថាវាជះឥទ្ធិពលលើមូលដ្ឋាននៃការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច របស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ផ្នែកមួយនៃការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដារសវនកម្ម តម្រូវឱ្យយើងខ្ញុំប្រើប្រាស់ការវិនិច្ឆ័យ និងរក្សាការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈក្នុងពេលបំពេញការងារសវនកម្មរបស់យើងខ្ញុំ ហើយយើងខ្ញុំ៖

- កំណត់ និងវាយតម្លៃហានិភ័យនៃភាពខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ដោយតាក់តែងនីតិវិធីសវនកម្ម និងធ្វើសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងស្វែងរកភស្តុតាងសវនកម្មគ្រប់គ្រាន់ និងសមស្រប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលបណ្តាលមកពីការរកមិនឃើញកំហុសជាសារវន្តពីការក្លែងបន្លំ វាមានទំហំធំជាងហានិភ័យដែលបណ្តាលមកពីកំហុសឆ្គងអចេតនា។ ការក្លែងបន្លំរួមមាន ការសមគំនិត ការក្លែងបន្លំឯកសារ ការលុបបំបាត់ដោយចេតនា ការបង្ហាញខុស ឬការរំលងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងសវនកម្ម ដើម្បីតាក់តែងនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនបញ្ចេញមតិយោបល់របស់យើងខ្ញុំទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារទេ។
- វាយតម្លៃអំពីភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ ភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងពាក់ព័ន្ធ ដែលគណៈគ្រប់គ្រងបានធ្វើឡើង។

- សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តរភាពអាជីវកម្ម របស់គណៈគ្រប់គ្រងអាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន ថាតើវាមានភាពមិនច្បាស់លាស់ជាសារវន្តដែលបានកើតឡើងកម្រិតណាពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានា អាចបណ្តាលឱ្យមានការសង្ស័យជាដុំកំភួន ទៅលើលទ្ធភាពរបស់ធនាគារ ក្នុងការបន្តនិរន្តរភាពអាជីវកម្មរបស់ខ្លួនដែរឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា វាមានភាពមិនច្បាស់លាស់ជាសារវន្តបានកើតឡើង នោះយើងខ្ញុំត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍សវនកម្ម ដើម្បីទាញចំណាប់អារម្មណ៍អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ចំពោះការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងនោះនៅមិនទាន់គ្រប់គ្រាន់ទៀត យើងខ្ញុំត្រូវធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ សេចក្តីសន្និដ្ឋានសរុបរបស់យើងខ្ញុំ អាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន រហូតដល់ ថ្ងៃចុះហត្ថលេខាលើរបាយការណ៍សវនកម្មនេះ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានាក្នុងពេលអនាគត អាចបណ្តាលឱ្យធនាគារឈប់បន្តនិរន្តរភាពអាជីវកម្ម។
- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងការលាតត្រដាងព័ត៌មានផ្សេងៗ និងកំណត់ថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ជាក់ស្តែង ដែលអាចធ្វើឱ្យមានការបង្ហាញត្រឹមត្រូវ។

យើងខ្ញុំបានរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចនូវបញ្ហាផ្សេងៗដូចជា ទំហំការងារ និងពេលវេលាសវនកម្មព្រមទាំងបញ្ហាសវនកម្មសំខាន់ៗរួមទាំងរាយការណ៍ពីភាពខ្វះខាតជាសារវន្តនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ។

**ង. ក្រុមហ៊ុន** PricewaterhouseCoopers (Cambodia) Ltd.




**គុយ លីម**
Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី29 ខែមីនា ឆ្នាំ2019

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក

## (អតីត ធនាគារឯកទេស តូម៉ាតូ)

## តារាងតុល្យការ

### សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

| | កំណត់សម្គាល់ | 2018 | | 2017 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 4 | 2,520 | 10,125 | 2,588 | 10,448 |
| សមតុល្យនៅធនាគារកណ្តាល | 5 | 1,051,372 | 4,224,413 | 435,084 | 1,756,434 |
| សមតុល្យនៅធនាគារផ្សេងៗ | 6 | 7,997,200 | 32,132,750 | 3,496,622 | 14,115,863 |
| ឥណទាន និងបុរេប្រទានអតិថិជន | 7 | 26,859,138 | 107,920,016 | 3,965,674 | 16,009,426 |
| ទ្រព្យសកម្មផ្សេងៗ | 8 | 588,230 | 2,363,508 | 78,925 | 318,619 |
| ទ្រព្យសម្បត្តិរឹបអូស | 9 | 636,253 | 2,556,465 | 1,392,400 | 5,621,119 |
| ការវិនិយោគ | 10 | 12,500 | 50,225 | 12,500 | 50,463 |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | 11 | 911,944 | 3,664,191 | 29,286 | 118,228 |
| ទ្រព្យសកម្មអរូបី | 12 | 15,892 | 63,854 | 14,786 | 59,691 |
| **ទ្រព្យសកម្មសរុប** | | 38,075,049 | 152,985,547 | 9,427,865 | 38,060,291 |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| បំណុលផ្សេងៗ | 13 | 660,287 | 2,653,033 | 203,100 | 819,915 |
| ប្រាក់កម្ចី | 14 | 18,000,000 | 72,324,000 | - | - |
| **បំណុលសរុប** | | 18,660,287 | 74,977,033 | 203,100 | 819,915 |
| **មូលធន** | | | | | |
| ដើមទុន | 15 | 18,750,000 | 75,337,500 | 8,100,000 | 32,699,700 |
| ចំណេញរក្សាទុក | | 664,762 | 2,671,014 | 1,124,765 | 4,540,676 |
| **មូលធនសរុប** | | 19,414,762 | 78,008,514 | 9,224,765 | 37,240,376 |
| **បំណុល និងមូលធនសរុប** | | 38,075,049 | 152,985,547 | 9,427,865 | 38,060,291 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីទំព័រទី 30 ដល់ទំព័រទី 68 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក

## (អតីត ធនាគារឯកទេស តូម៉ាតូ)

## របាយការណ៍លទ្ធផល

### សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

| | កំណត់សម្គាល់ | 2018 ដុល្លារអាមេរិក | 2018 ពាន់រៀល | 2017 ដុល្លារអាមេរិក | 2017 ពាន់រៀល |
|---|---|---|---|---|---|
| ចំណូលការប្រាក់ | 16 | 1,374,402 | 5,522,347 | 598,573 | 2,416,439 |
| ចំណាយការប្រាក់ | | (74,613) | (299,795) | - | - |
| **ចំណូលការប្រាក់-សុទ្ធ** | | 1,299,789 | 5,222,552 | 598,573 | 2,416,439 |
| សំវិធានធនសម្រាប់ការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃឥណទាន បុរេប្រទាន និងហិរញ្ញប្បទាន | | (235,600) | (946,641) | (38,605) | (155,849) |
| **ចំណូលការប្រាក់សុទ្ធ បន្ទាប់ពីកាត់កងសំវិធានធនសម្រាប់ការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃឥណទាន បុរេប្រទាន និងហិរញ្ញប្បទាន** | | 1,064,189 | 4,275,911 | 559,968 | 2,260,590 |
| ចំណូលសោហ៊ុយ និងកម្រៃជើងសា | 17 | 283,820 | 1,140,389 | 49,933 | 201,580 |
| ចំណូលផ្សេងៗ | 18 | 65,053 | 261,383 | 58,631 | 236,693 |
| **ចំណូលប្រតិបត្តិការផ្សេងៗ** | | 1,413,062 | 5,677,683 | 668,532 | 2,698,863 |
| ចំណាយបុគ្គលិក | 19 | (1,008,701) | (4,052,961) | (307,892) | (1,242,960) |
| ចំណាយរដ្ឋបាល និងចំណាយប្រតិបត្តិការ | 20 | (744,777) | (2,992,514) | (476,161) | (1,922,262) |
| ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | 11 | (115,093) | (462,444) | (7,154) | (28,881) |
| ចំណាយរំលស់ទ្រព្យសកម្មអរូបី | 12 | (4,494) | (18,057) | (4,569) | (18,445) |
| | | (1,873,065) | (7,525,976) | (795,776) | (3,212,548) |
| **ខាតមុនបង់ពន្ធលើប្រាក់ចំណូល** | | (460,003) | (1,848,293) | (127,244) | (513,685) |
| ចំណាយពន្ធលើប្រាក់ចំណូល | 21 | - | - | - | - |
| **ខាតក្នុងឆ្នាំ** | | (460,003) | (1,848,293) | (127,244) | (513,685) |
| **សម្រាប់បែងចែកឱ្យម្ចាស់ធនាគារ** | | (460,003) | (1,848,293) | (127,244) | (513,685) |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីទំព័រទី 30 ដល់ទំព័រទី 68 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## របាយការណ៍បម្រែបម្រួលមូលធន
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

| | សម្រាប់បែងចែកឱ្យម្ចាស់ធនាគារ | | |
|---|---|---|---|
| | ដើមទុន<br>ដុល្លារអាមេរិក | ចំណេញរក្សាទុក<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
| **សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2017** | | | |
| នៅថ្ងៃទី01 ខែមករា ឆ្នាំ2017 | 8,100,000 | 1,252,009 | 9,352,009 |
| ខាតក្នុងឆ្នាំ | - | (127,244) | (127,244) |
| **គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2017** | 8,100,000 | 1,124,765 | 9,224,765 |
| **គិតជាពាន់រៀល** | 32,699,700 | 4,540,676 | 37,240,376 |
| **សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018** | | | |
| នៅថ្ងៃទី01 ខែមករា ឆ្នាំ2018 | 8,100,000 | 1,124,765 | 9,224,765 |
| ការបន្ថែមដើមទុន | 10,650,000 | - | 10,650,000 |
| ខាតក្នុងឆ្នាំ | - | (460,003) | (460,003) |
| **គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2018** | 18,750,000 | 664,762 | 19,414,762 |
| **គិតជាពាន់រៀល** | 75,337,500 | 2,671,014 | 78,008,514 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីទំព័រទី 30 ដល់ទំព័រទី 68ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក

## (អតីត ធនាគារឯកទេស តូម៉ាតូ)

## របាយការណ៍លំហូរសាច់ប្រាក់

### សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

| | កំណត់សម្គាល់ | 2018 ដុល្លារអាមេរិក | 2018 ពាន់រៀល | 2017 ដុល្លារអាមេរិក | 2017 ពាន់រៀល |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងប្រតិបត្តិការ | 22 | (28,273,471) | (113,602,806) | (816,998) | (3,298,220) |
| ការប្រាក់បានទទួល | | 1,236,171 | 4,966,935 | 608,333 | 2,455,840 |
| ការប្រាក់បានបង់ | | (39,776) | (159,820) | - | - |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពប្រតិបត្តិការ | | (27,077,076) | (108,795,691) | (208,665) | (842,380) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | | (1,020,865) | (4,101,836) | (8,291) | (33,471) |
| ការទិញទ្រព្យសកម្មអរូបី | | (5,600) | (22,501) | (1,539) | (6,213) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | 1,120 | 4,500 | - | - |
| ប្រាក់តម្កល់ធានាលើដើមទុន | | (532,500) | (2,139,585) | - | - |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ | | (1,557,845) | (6,259,422) | (9,830) | (39,684) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់ពីប្រាក់កម្ចី | | 18,000,000 | 72,324,000 | - | - |
| សាច់ប្រាក់ពីការបន្ថែមដើមទុន | | 10,650,000 | 42,791,700 | - | - |
| សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន | | 28,650,000 | 115,115,700 | - | - |
| **កំណើន/(តំហយ)សាច់ប្រាក់និងសាច់ប្រាក់សមមូល - សុទ្ធ** | | 15,079 | 60,587 | (218,495) | (882,064) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមឆ្នាំ | | 2,179,294 | 8,797,810 | 2,397,789 | 9,679,874 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (41,407) | - | - |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងឆ្នាំ** | 23 | 2,194,373 | 8,816,990 | 2,179,294 | 8,797,810 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីទំព័រទី 30 ដល់ទំព័រទី 68 ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

### 1. ព័ត៌មានទូទៅ

ធនាគារបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី24 ខែមិថុនា ឆ្នាំ2008 ក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ Co.5029E/2008 ចេញដោយក្រសួងពាណិជ្ជកម្ម។ ធនាគារបានទទួលអាជ្ញាប័ណ្ណជាធនាគារឯកទេស ពីធនាគារជាតិ នៃ កម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") នៅថ្ងៃទី10 ខែកក្កដា ឆ្នាំ2008 ដើម្បីធ្វើប្រតិបត្តិការជាធនាគារឯកទេស។

ធនាគារបានប្តូរនាមករណ៍របស់ខ្លួនពី "ធនាគារឯកទេស តូម៉ាតូ" ទៅជា "ធនាគារឯកទេស ខេប៊ី ដេហាន ម.ក" នៅថ្ងៃទី23 ខែមីនា ឆ្នាំ2018 ដោយទទួលបានការអនុម័តពីធនាគារកណ្តាល។ ធនាគារបានទទួលបានអាជ្ញាប័ណ្ណថ្មីអំពីនាមករណ៍ថ្មីរបស់ខ្លួន ដែលត្រូវបានអនុម័តដោយធនាគារកណ្តាលនៅថ្ងៃទី22 ខែមីនា ឆ្នាំ2018។

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារគឺការផ្តល់ឥណទានទិញយានយន្ត និងឥណទានទូទៅ ដល់សហគ្រាសធុនតូច និងមធ្យម ដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅជាន់ទី21 និង 22 នៃអគារលេខមួយ ផ្លូវលេខ 360 សង្កាត់ បឹងកេងកង1 ខណ្ឌ បឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ធនាគារមានបុគ្គលិកចំនួន 89 នាក់ (2017 ៖ 22 នាក់)។

ក្រុមប្រឹក្សាភិបាលបានអនុម័តឱ្យចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុ នៅថ្ងៃទី22 ខែមីនា ឆ្នាំ2019។

### 2. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗ ដែលបានអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញដូចខាងក្រោម។ គោលការណ៍ទាំងនេះត្រូវបានអនុវត្តយ៉ាងស៊ីសង្វាក់គ្នាគ្រប់ឆ្នាំដែលបានដាក់បង្ហាញទាំងអស់ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

#### 2.1 មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំដោយប្រើវិធីសាស្ត្រថ្លៃដើម និងអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារកណ្តាល និងស្តង់ដារគណនេយ្យកម្ពុជា (ហៅកាត់ថា "CAS")។ ក្នុងការអនុវត្ត CAS ធនាគារក៏បានអនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ នៃកម្ពុជា (ហៅកាត់ថា "CFRS") គឺ ស្តង់ដារ CFRS 7 ស្តីពី "ការលាតត្រដាងព័ត៌មានអំពីឧបករណ៍ហិរញ្ញវត្ថុ"។ គោលការណ៍គណនេយ្យដែលបានប្រើប្រាស់ អាចមានភាពខុសគ្នាពីគោលការណ៍គណនេយ្យដែលត្រូវបានទទួលស្គាល់ និងប្រើប្រាស់ជាទូទៅនៅតាមបណ្តាប្រទេស និងយុត្តាធិការផ្សេងៗ។ របាយការណ៍ហិរញ្ញវត្ថុនេះ មិនមានបំណងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់ ដោយអនុលោមទៅតាមយុត្តាធិការណាផ្សេង ក្រៅពីព្រះរាជាណាចក្រកម្ពុជានោះទេ។ ដូចនេះរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ សម្រាប់បង្ហាញចំពោះតែអ្នកដែលបានជ្រាបអំពីគោលការណ៍គណនេយ្យ នីតិវិធី និងការអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលស្របទៅតាមគោលការណ៍ណែនាំរបស់ធនាគារកណ្តាល និង CAS តម្រូវឱ្យប្រើប្រាស់ការប៉ាន់ស្មាន និងការសន្មត ដែលមានផលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និងបំណុល និងការលាតត្រដាងទ្រព្យសកម្ម និងបំណុលយថាភាពដែលបានរាយការណ៍ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ និងប៉ះពាល់ដល់ចំនួននៃប្រាក់ចំណូល និងចំណាយដែលបានរាយការណ៍នៅក្នុងការិយបរិច្ឆេទរាយការណ៍នេះ។ ទោះបីជាការប៉ាន់ស្មានទាំងនេះ ផ្អែកទៅលើកម្រិតនៃការយល់ដឹងរបស់គណៈគ្រប់គ្រង ទៅលើព្រឹត្តិការណ៍ និងសកម្មភាពផ្សេងៗនាពេលបច្ចុប្បន្នក៏ដោយ ក៏លទ្ធផលជាក់លាក់ចុងក្រោយអាចខុសពីការប៉ាន់ស្មានទាំងនេះ។ ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់3នៃរបាយការណ៍ហិរញ្ញវត្ថុ។

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

### 2. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.2 ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុថ្មី

នៅថ្ងៃទី28 ខែសីហា ឆ្នាំ2009 ក្រុមប្រឹក្សាជាតិគណនេយ្យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រកាសដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលផ្អែកទាំងស្រុងទៅតាមស្តង់ដារទាំងអស់ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ (ហៅកាត់ថា "IASB") រួមទាំង បំណកស្រាយ និងវិសោធនកម្មពាក់ព័ន្ធផ្សេងៗ។ អង្គភាពដែលមានការទទួលខុសត្រូវជាសាធារណៈ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឱ្យស្របទៅតាម CIFRS សម្រាប់ការិយបរិច្ឆេទគណនេយ្យដែលចាប់ផ្តើមនៅថ្ងៃទី01 ខែមករា ឆ្នាំ2012 ឬការិយបរិច្ឆេទគណនេយ្យបន្ទាប់ពីនេះ។

សារាចរណែនាំលេខ 058 សហវ-កជគ ចុះថ្ងៃទី24 ខែមីនា ឆ្នាំ2016 ក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអនុញ្ញាតឱ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ពន្យារពេលអនុវត្ត CIFRS បន្ថែមទៀត រហូតដល់ការិយបរិច្ឆេទដែលចាប់ផ្តើមនៅថ្ងៃទី01 ខែមករា ឆ្នាំ2019 ឬការិយបរិច្ឆេទបន្ទាប់ពីនេះ។ ធនាគារត្រូវបានតម្រូវឱ្យអនុវត្ត CIFRS ចំពោះរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដែលចាប់ផ្តើមនៅថ្ងៃទី01 ខែមករា ឆ្នាំ2019។ ការអនុវត្តតាមស្តង់ដារ CAS ដែលជាស្តង់ដារគណនេយ្យដែលបានប្រើប្រាស់នាពេលបច្ចុប្បន្ន មានភាពខុសគ្នាពីស្តង់ដារ CIFRS ជាច្រើន។ ដូច្នេះការអនុវត្តតាមស្តង់ដារ CIFRS នឹងមានផលប៉ះពាល់ខ្លះៗលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។ ធនាគារកំពុងតែធ្វើការវាយតម្លៃអំពីផលប៉ះពាល់ក្នុងការអនុវត្តស្តង់ដារ CIFRS ។

### 2.3 ប្រតិបត្តិការប្តូររូបិយប័ណ្ណ

#### (ក) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានវាស់វែងដោយប្រើរូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បងដែលធនាគារធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល")។ ប្រាក់ដុល្លារអាមេរិកឆ្លុះបញ្ចាំងនូវធាតុសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងកាលៈទេសៈនានាដ៏មានសារសំខាន់របស់ធនាគារ ដូចនេះរបាយការណ៍ហិរញ្ញវត្ថុនេះត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញរបស់ធនាគារ។

#### (ខ) ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានកត់ត្រាប្តូរទៅជាប្រាក់ដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាត បណ្តាលមកពីការទូទាត់តាមប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានា ដែលកំណត់ជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់នាដំណាច់ឆ្នាំ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

#### (គ) ការបង្ហាញជាប្រាក់រៀល

អនុលោមតាមប្រកាសរបស់ធនាគារកណ្តាល លេខ ធ7-07-164ប្រ.ក ចុះថ្ងៃទី13 ខែធ្នូ ឆ្នាំ2007 តម្រូវឱ្យមានការប្តូរពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ចំពោះតារាងតុល្យការ របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធនភាគទុនិក របាយការណ៍លំហូរសាច់ប្រាក់ និងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 និងសម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ដោយប្រើអត្រាប្តូរប្រាក់ផ្លូវការមធ្យម ដែលផ្សព្វផ្សាយដោយធនាគារកណ្តាល នាកាលបរិច្ឆេទរាយការណ៍ដែល 1ដុល្លារអាមេរិក ស្មើនឹង 4,018 រៀល (31 ធ្នូ 2017 ៖ 1ដុល្លារ អាមេរិក ស្មើនឹង 4,037 រៀល)។ តួលេខដែលត្រូវបានប្តូរនេះមិនត្រូវបានធ្វើសវនកម្មទេ ហើយមិនគួរបកស្រាយថាតួលេខនេះជាតួលេខសម្រាប់ដាក់បង្ហាញ ដូចតួលេខជាប្រាក់ដុល្លារអាមេរិក ឬយល់ថាជាតួលេខត្រូវបានប្តូរ ឬអាចប្តូរទៅជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ខាងលើ ឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ។

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## 2. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.4 សាច់ប្រាក់ និងសាច់ប្រាក់សមមូល

ក្នុងការរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ គណនីសាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សមតុល្យដែលមានកាលកំណត់ដើមបីខែ ឬតិចជាងបីខែ រួមទាំង សាច់ប្រាក់ក្នុងដៃ សមតុល្យមិនជាប់កម្រិតនៅធនាគារកណ្តាល និងសមតុល្យនៅធនាគារផ្សេងៗ។

### 2.5 ឥណទាន និងបុរេប្រទានអតិថិជន

ឥណទាន និងបុរេប្រទានអតិថិជន ត្រូវបានរាយការណ៍ក្នុងតារាងតុល្យការ តាមចំនួនទឹកប្រាក់ដើមដែលនៅមិនទាន់ទូទាត់ ដកចំនួនដែលបានជម្រះចេញពីបញ្ជី និងសំវិធានធនឥណទាន និងបុរេប្រទានបាត់បង់។ ឥណទាន និងបុរេប្រទានត្រូវបានជម្រះចេញពីបញ្ជី នៅពេលដែលគ្មានលទ្ធភាពជាក់លាក់ថានឹងអាចប្រមូលបានមកវិញ។ ឥណទាន និងបុរេប្រទានអតិថិជនដែលប្រមូលបានមកវិញបន្ទាប់ពីត្រូវបានជម្រះចេញពីបញ្ជី ឬត្រូវបានកត់ត្រាសំវិធានធនសម្រាប់ការថយចុះតម្លៃឥណទានបាត់បង់រួចហើយ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

### 2.6 សំវិធានធនហ្វាស៊ីលីធីហិរញ្ញវត្ថុ

ធនាគារបានអនុវត្តតាមចំណាត់ថ្នាក់ហ្វាស៊ីលីធីហិរញ្ញវត្ថុ និងសំវិធានធន ទៅតាមការតម្រូវនៃប្រកាសរបស់ធនាគារកណ្តាលលេខ ធ7-017-344ប្រ.ក ចុះថ្ងៃទី01 ខែធ្នូ ឆ្នាំ2017 និងសារាចរណែនាំលេខ ធ7-018-001 ស.រ.ច.ណ ចុះថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2018 ស្តីពី “ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអឹមតែរមិន” សម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។ ឥណទាន និងបុរេប្រទាន និងផលិតផលហិរញ្ញវត្ថុផ្សេងៗ ត្រូវបានបែងចែកជាប្រាំថ្នាក់ ហើយត្រូវកត់ត្រាសំវិធានធនអប្បបរមាអាស្រ័យទៅតាមចំណាត់ថ្នាក់របស់វា ដោយមិនគិតដល់ទ្រព្យសកម្មដែលត្រូវបានដាក់ជាទ្រព្យធានា (លើកលែងតែសាច់ប្រាក់) លុះត្រាតែមានព័ត៌មានផ្សេងទៀតដែលបង្ហាញពីស្ថានភាពអាក្រក់ជាងនេះ។ សំវិធានធនឥណទាន និងបុរេប្រទានត្រូវបានបង្ហាញដោយការកាត់បន្ថយចំនួនទឹកប្រាក់ពីឥណទាន និងបុរេប្រទាន។ សំវិធានធនសមតុល្យនៅធនាគារផ្សេងៗ ត្រូវបានបង្ហាញដោយការកាត់បន្ថយចំនួនទឹកប្រាក់ពីសមតុល្យនៅធនាគារផ្សេងៗ។

តារាងខាងក្រោមនេះបង្ហាញពីចំណាត់ថ្នាក់ឥណទាន និង សំវិធានធនអប្បបរមាតាមតម្រូវការ៖

| ចំណាត់ថ្នាក់ហ្វាស៊ីលីធី | ចំនួនថ្ងៃផុតកំណត់ | សំវិធានធន |
|---|---|---|
| **រយៈពេលខ្លី** | | |
| សំវិធានធនទូទៅ: | | |
| ឥណទានធម្មតា | ក្រោម 15 ថ្ងៃ | 1% |
| សំវិធានធនជាក់លាក់: | | |
| ឥណទានឃ្លាំមើល | 15 ថ្ងៃ - 30 ថ្ងៃ | 3% |
| ឥណទានក្រោមស្តង់ដារ | 31 ថ្ងៃ - 60 ថ្ងៃ | 20% |
| ឥណទានសង្ស័យ | 61 ថ្ងៃ - 90 ថ្ងៃ | 50% |
| ឥណទានបាត់បង់ | 91 ថ្ងៃ ឬលើស | 100% |
| **រយៈពេលវែង** | | |
| សំវិធានធនទូទៅ: | | |
| ឥណទានធម្មតា | 0 ថ្ងៃ - 29 ថ្ងៃ | 1% |
| សំវិធានធនជាក់លាក់: | | |
| ឥណទានឃ្លាំមើល | 30 ថ្ងៃ - 89 ថ្ងៃ | 3% |
| ឥណទានក្រោមស្តង់ដារ | 90 ថ្ងៃ - 179 ថ្ងៃ | 20% |
| ឥណទានសង្ស័យ | 180 ថ្ងៃ - 359 ថ្ងៃ | 50% |
| ឥណទានបាត់បង់ | 360 ថ្ងៃ ឬលើស | 100% |

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## 2. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.7 ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាថ្លៃដើម ដករំលស់បង្គរ លើកលែងតែដីធ្លី ដែលមិនដករំលស់។ ថ្លៃដើមរួមមានចំណាយផ្ទាល់ផ្សេងៗ ក្នុងការទិញទ្រព្យសកម្មនោះ។ ចំណាយបន្តបន្ទាប់ផ្សេងៗ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យនោះ ឬត្រូវបានកត់ត្រាជាទ្រព្យសកម្មដាច់ដោយឡែក តាមការសមស្របតែនៅពេលដែលមានភាពប្រាកដប្រជាថា ផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃទ្រព្យនោះនឹងហូរចូលមកក្នុងធនាគារ ហើយថ្លៃដើមនៃទ្រព្យនោះអាចត្រូវបានវាស់វែងគួរឱ្យជឿជាក់បានតែប៉ុណ្ណោះ។ ចំណាយលើការជួសជុល និងការថែទាំផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផលក្នុងឆ្នាំដែលប្រតិបត្តិការនោះបានកើតឡើង។ ការធ្វើរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានគណនាតាមវិធីសាស្ត្ររំលស់ថយចុះ លើកលែងតែការកែលម្អទ្រព្យជួលដែលត្រូវបានដករំលស់តាមវិធីសាស្ត្ររំលស់ថេរ អាស្រ័យទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសកម្មនីមួយៗដូចខាងក្រោម៖

| ចំណាត់ថ្នាក់ | អត្រារំលស់ |
|---|---|
| ការកែលម្អទ្រព្យជួល | 20% |
| បរិក្ខារការិយាល័យ | 20% - 25% |
| គ្រឿងសង្ហារិម និង បរិក្ខារបំពាក់ | 20% - 25% |
| បរិក្ខារកុំព្យូទ័រ | 50% |
| យានយន្ត | 20% |

តម្លៃសំណល់ និងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យ និងកែសម្រួលតាមការសមស្របនៅរៀងរាល់ដំណាច់ការិយបរិច្ឆេទរាយការណ៍នីមួយៗ។ តម្លៃយោងនៃទ្រព្យសកម្មណាមួយ ដែលលើសពីតម្លៃប៉ាន់ស្មានដែលអាចស្រង់មកវិញបានរបស់វាត្រូវបានកត់ត្រាបន្ថយភ្លាមឱ្យនៅត្រឹមតម្លៃដែលអាចស្រង់មកវិញបាន។ ចំណេញ និងខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបតម្លៃលក់បាន ជាមួយនឹងតម្លៃយោង និងត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។ ការងារកំពុងដំណើរការមិនត្រូវបានដករំលស់ទេ រហូតដល់ពេលដែលទ្រព្យសកម្មដែលពាក់ព័ន្ធទាំងនេះ ត្រូវបានបញ្ចប់រួចរាល់សម្រាប់ដាក់ឱ្យប្រើប្រាស់ក្នុងប្រតិបត្តិការ។

### 2.8 ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីរួមមាន អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ និងចំណាយពាក់ព័ន្ធត្រូវបានរាយការណ៍តាមថ្លៃដើមដករំលស់បង្គរ និងការខាតដែលបណ្តាលមកពីការថយចុះតម្លៃ។ អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានកើតឡើងដើម្បីទិញកម្មវិធីនោះមកប្រើប្រាស់។ ថ្លៃដើមត្រូវបានធ្វើរំលស់ក្នុងរយៈពេល10ឆ្នាំ ដោយប្រើវិធីសាស្ត្ររំលស់ថេរ។

### 2.9 ភតិសន្យា

ភតិសន្យាដែលហានិភ័យមួយផ្នែកធំ និងផលនៃកម្មសិទ្ធិលើទ្រព្យសកម្មនេះ ត្រូវបានរក្សាដោយភាគីម្ចាស់ទ្រព្យ ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិ។ ការទូទាត់ភតិសន្យាប្រតិបត្តិ ត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋានថេរ អាស្រ័យទៅតាមរយៈពេលនៃភតិសន្យានោះ។

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

### 2. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.10 ការថយចុះតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មទាំងឡាយណាដែលមានអាយុកាលប្រើប្រាស់មិនកំណត់ មិនត្រូវបានធ្វើរំលស់ទេ ហើយវាត្រូវបានត្រួតពិនិត្យប្រចាំឆ្នាំ ដើម្បីរកការថយចុះតម្លៃរបស់វា។ ទ្រព្យសកម្មទាំងឡាយណាដែលត្រូវធ្វើរំលស់ ត្រូវបានត្រួតពិនិត្យរកការថយចុះរបស់វា នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយចង្អុលបង្ហាញថាតម្លៃយោងរបស់វានឹងមិនអាចស្រង់មកវិញបាន។ ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាតាមចំនួនលម្អៀងរវាងតម្លៃយោង ដែលលើសពីតម្លៃដែលអាចស្រង់មកវិញបានរបស់ទ្រព្យនោះ។ តម្លៃដែលអាចស្រង់មកវិញបាន គឺជាតម្លៃមួយណា ដែលខ្ពស់ជាងគេរវាងតម្លៃសមស្របនៃទ្រព្យនោះ ដកចំណាយក្នុងការលក់ និងតម្លៃនៅប្រើប្រាស់។

ការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផលក្នុងឆ្នាំដែលវាបានកើតឡើង។ ការកត់ត្រាការខាតដែលបណ្តាលមកពីការថយចុះតម្លៃត្រលប់មកវិញ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលទៅតាមចំនួនតម្លៃយោងរបស់ទ្រព្យសកម្ម ដែលមិនលើសពីតម្លៃយោងដែលត្រូវបានកំណត់រួច កាត់កងជាមួយនឹងរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី ប្រសិនបើមិនបានកត់ត្រាការខាតដែលបណ្តាលមកពីការថយចុះតម្លៃ។

### 2.11 សំវិធានធន

សំវិធានធនត្រូវបានកត់ត្រា នៅពេលដែលធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់នាពេលបច្ចុប្បន្នឬកាតព្វកិច្ចប្រយោលដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ដែលទំនងជាអាចតម្រូវឱ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់ត្រូវបានប៉ាន់ស្មានគួរឱ្យជឿជាក់បាន។ នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើនកម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះត្រូវបានកំណត់ដោយគិតទៅលើចំណាត់ថ្នាក់នៃកាតព្វកិច្ចនោះទាំងមូល។

សំវិធានធនត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្ននៃចំណាយដែលរំពឹងថាត្រូវទូទាត់កាតព្វកិច្ចនោះ ដោយប្រើអត្រាមុនបង់ពន្ធដើម្បីឆ្លុះបញ្ចាំងអំពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃសាច់ប្រាក់គិតតាមពេលវេលានិងហានិភ័យជាក់លាក់ផ្សេងៗនៃកាតព្វកិច្ចនោះ។ ការកើនឡើងនៃសំវិធានធនដោយសារពេលវេលាដែលបានកន្លងផុត ត្រូវបានកត់ត្រាជាចំណាយការប្រាក់។

### 2.12 ចំណូលការប្រាក់

ចំណូលការប្រាក់បានមកពីឥណទាន និងបុរេប្រទានអតិថិជន សមតុល្យនៅធនាគារកណ្តាល និងសមតុល្យនៅធនាគារផ្សេងៗ ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ លើកលែងតែមានការសង្ស័យគួរឱ្យបារម្ភចំពោះការប្រមូលឥណទាន និងបុរេប្រទានអតិថិជនមកវិញ ដែលក្នុងករណីនេះការប្រាក់ត្រូវបានព្យួរសិន រហូតដល់ពេលទទួលបានសាច់ប្រាក់ជាក់ស្តែង។ គោលការណ៍ក្នុងការព្យួរការប្រាក់ គឺអនុលោមស្របទៅតាមគោលការណ៍ណែនាំរបស់ធនាគារកណ្តាល ស្តីពី ការព្យួរការប្រាក់លើឥណទានមិនដំណើរការ និងសំវិធានធនឥណទានបាត់បង់។

### 2.13 ចំណូលកម្រៃជើងសា

ជាទូទៅ កម្រៃជើងសាត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ នៅពេលដែលធនាគារបានផ្តល់សេវាជូនអតិថិជន។ កម្រៃដំណើរការឥណទានត្រូវបានកត់ត្រាជាចំណូល នៅពេលដែលធនាគារបានផ្តល់ឥណទានជូនអតិថិជន។

### 2.14 ចំណាយការប្រាក់

ចំណាយការប្រាក់លើទឹកប្រាក់ជំពាក់ធនាគារផ្សេងៗ ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ។

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

### 2. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### 2.15 អត្ថប្រយោជន៍បុគ្គលិក

**អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី**

អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លីត្រូវបានកត់ត្រាបង្គរ ក្នុងឆ្នាំដែលបុគ្គលិកបានបម្រើការងារជូនធនាគារ។

**អត្ថប្រយោជន៍បុគ្គលិករយៈពេលវែងផ្សេងៗ - ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ**

វិសោធនកម្មលើច្បាប់ស្តីពីការងារ ចុះថ្ងៃទី26 ខែមិថុនា ឆ្នាំ2018 និងប្រកាសរបស់ក្រសួងលេខ 443 ក.ប/ ប្រ.ក ចុះថ្ងៃទី21 ខែកញ្ញា ឆ្នាំ2018 បានណែនាំឱ្យគ្រឹះស្ថាន សហគ្រាសឯកជនទាំងអស់ ទូទាត់ប្រាក់បំណាច់អតីតភាពការងារចាប់ពីថ្ងៃទី01 ខែមករា ឆ្នាំ2019 ដោយត្រូវទូទាត់រៀងរាល់ប្រាំមួយខែម្តង នៅថ្ងៃទី30 ខែមិថុនា និង ថ្ងៃទី31 ខែធ្នូ ចំពោះបុគ្គលិកដែលមានកិច្ចសន្យាការងារអចិន្ត្រៃយ៍។ ប្រកាសនេះក៏បានណែនាំឱ្យទូទាត់ប្រាក់បំណាច់អតីតភាពការងាររំឭក សម្រាប់បុគ្គលិកដែលបានបម្រើការងារជូនធនាគារមុនថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ហើយនៅបន្តបម្រើការងារក្នុងធនាគារ។ ការទូទាត់ប្រាក់បំណាច់អតីតភាពការងាររំឭក អាស្រ័យទៅតាមចំនួនឆ្នាំដែលបុគ្គលិកម្នាក់បានបម្រើការងារជូនធនាគារ ហើយមិនត្រូវលើសពី6ខែនៃប្រាក់បៀវត្សរ៍ជុលមធ្យមទេ។ ប្រាក់បំណាច់អតីតភាពការងាររំឭកនេះ ត្រូវបង់ឱ្យបុគ្គលិកចំនួន 7.5 ថ្ងៃ រៀងរាល់6ខែម្តង ផ្តួបជាមួយនឹងប្រាក់បំណាច់អតីតភាពការងារថ្មី។

បំណុលប្រាក់បំណាច់អតីតភាពការងាររំឭក ត្រូវបានកត់ត្រាតាមតម្លៃបច្ចុប្បន្ននៃចំនួនទឹកប្រាក់ដែលរំពឹងថាត្រូវទូទាត់នាការិយបរិច្ឆេទរាយការណ៍ ដែលធនាគារត្រូវបង់ឱ្យបុគ្គលិក ជាថ្នូរនឹងការបម្រើការងារជូនធនាគារក្នុងពេលបច្ចុប្បន្ន ហើយចំនួនទឹកប្រាក់នេះត្រូវបានប៉ាន់ស្មានគួរឱ្យជឿជាក់បាន។ កាតព្វកិច្ចនេះកើតឡើង នៅពេលដែលបុគ្គលិកបានបម្រើការងារជូនធនាគារ ហើយធនាគាររំពឹងថាត្រូវទូទាត់ប្រាក់បំណាច់នេះក្នុងការិយបរិច្ឆេទរាយការណ៍នាពេលអនាគត។

### 2.16 ពន្ធលើប្រាក់ចំណូលក្នុងគ្រា និងពន្ធពន្យារលើប្រាក់ចំណូល

បន្ទុកពន្ធលើប្រាក់ចំណូលក្នុងគ្រា ត្រូវបានគណនាតាមមូលដ្ឋានច្បាប់សារពើពន្ធ ដែលបានអនុម័តជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទរាយការណ៍នៅក្នុងប្រទេសដែលធនាគារធ្វើប្រតិបត្តិការ និងបង្កើតប្រាក់ចំណូលជាប់ពន្ធ។ ពន្ធពន្យារត្រូវបានធ្វើសំវិធានធន ដោយប្រើវិធីសាស្ត្របំណុលក្នុងតារាងតុល្យការ លើលម្អៀងបណ្តោះអាសន្ននៃតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ធៀបនឹងចំនួនដែលបានប្រើប្រាស់សម្រាប់គោលដៅពន្ធ។ ពន្ធពន្យារត្រូវបានវាស់វែងតាមអត្រាពន្ធដែលរំពឹងថាត្រូវអនុវត្តចំពោះលម្អៀងបណ្តោះអាសន្ន នៅពេលដែលវាត្រូវបានកត់ត្រាត្រលប់មកវិញ អាស្រ័យទៅតាមច្បាប់សារពើពន្ធដែលបានអនុម័តជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទរាយការណ៍។

ពន្ធពន្យារទ្រព្យសកម្មត្រូវបានទូទាត់ជាមួយនឹងបំណុលពន្ធពន្យារ ប្រសិនបើធនាគារមានសិទ្ធិតាមផ្លូវច្បាប់ ដើម្បីទូទាត់បំណុលពន្ធក្នុងគ្រា ជាមួយនឹងពន្ធពន្យារទ្រព្យសកម្ម ហើយប្រសិនបើវាទាក់ទងនឹងពន្ធលើប្រាក់ចំណូលដែលកំណត់ដោយអាជ្ញាធរពន្ធដារតែមួយ ទៅលើអង្គភាពជាប់ពន្ធតែមួយ។

ពន្ធពន្យារទ្រព្យសកម្មត្រូវបានកត់ត្រា លុះត្រាតែមានភាពប្រាកដថាធនាគារនឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ដើម្បីយកលម្អៀងបណ្តោះអាសន្នមកប្រើប្រាស់។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ហើយត្រូវបានកត់ត្រាបន្ថយ ប្រសិនបើមិនមានភាពប្រាកដថានឹងមានអត្ថប្រយោជន៍ពន្ធពាក់ព័ន្ធត្រូវបានទទួលស្គាល់។

### 2.17 ទ្រព្យសម្បត្តិរឹបអូស

ក្នុងកាលៈទេសៈជាក់លាក់ ទ្រព្យសម្បត្តិត្រូវបានរឹបអូសចំពោះឥណទានដែលមិនបានសងប្រាក់។ ទ្រព្យសម្បត្តិរឹបអូសត្រូវបានវាស់វែងតាមតម្លៃមួយណាដែលទាបជាងគេ រវាងតម្លៃយោង និងតម្លៃសមស្របដកចំណាយក្នុងការលក់។

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

### 2. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

#### 2.18 ប្រតិបត្តិការភាគីពាក់ព័ន្ធ

ភាគីដែលត្រូវបានចាត់ទុកថាមានការពាក់ព័ន្ធ ប្រសិនបើភាគីនោះមានលទ្ធភាពដោយផ្ទាល់ ឬដោយប្រយោល ក្នុងការគ្រប់គ្រងភាគីមួយផ្សេងទៀត ឬមានឥទ្ធិពលជាសារវន្តលើភាគីមួយផ្សេងទៀត ក្នុងការសម្រេចចិត្តលើផ្នែកប្រតិបត្តិការ និងហិរញ្ញវត្ថុ ឬប្រសិនបើភាគីមួយ និងភាគីផ្សេងទៀត ស្ថិតនៅក្រោមការគ្រប់គ្រងរួម ឬស្ថិតនៅក្រោមឥទ្ធិពលរួមរបស់ក្រុមហ៊ុនមេតែមួយ។ ភាគីពាក់ព័ន្ធអាចជាឯកបុគ្គល ឬជាក្រុមហ៊ុន រាប់ទាំងសមាជិកគ្រួសារជិតស្និទ្ធរបស់បុគ្គលនោះក៏ត្រូវបានចាត់ទុកជាភាគីពាក់ព័ន្ធដែរ។ អនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុភាគីពាក់ព័ន្ធត្រូវបានឱ្យនិយមន័យថាជាភាគីទាំងឡាយណាដែលកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោល យ៉ាងហោចណាស់10% នៃដើមទុនរបស់ធនាគារ ឬមានសិទ្ធិបោះឆ្នោត រួមទាំងឯកបុគ្គលដែលមានតួនាទីក្នុងអភិបាលកិច្ច ការដឹកនាំ ការគ្រប់គ្រង ឬការត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារ។

### 3. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ធនាគារធ្វើការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ដែលមានផលប៉ះពាល់ដល់ចំនួនទឹកប្រាក់ទ្រព្យសកម្ម និងបំណុលដែលបានរាយការណ៍។ ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ត្រូវបានវាយតម្លៃជាបន្តបន្ទាប់ ដោយផ្អែកទៅតាមបទពិសោធន៍ក្នុងគ្រាកន្លងមក និងកត្តាផ្សេងៗទៀត រួមទាំង ការរំពឹងទុកអំពីព្រឹត្តិការណ៍នាពេលអនាគត ដែលគេជឿជាក់ថាមានភាពសមហេតុផល ទៅតាមកាលៈទេសៈផ្សេងៗ។

#### (ក) ការខាតបង់បណ្តាលមកពីការថយចុះតម្លៃនៃហ្វាស៊ីលីធីហិរញ្ញវត្ថុ

ធនាគារបានអនុវត្តតាមការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន ដែលតម្រូវដោយប្រកាសរបស់ធនាគារកណ្តាលលេខ ធ7-017-344 ប្រ.ក ចុះថ្ងៃទី01 ខែធ្នូ ឆ្នាំ 2017 និងសារាចរណែនាំលេខ ធ7-018-001 ស.រ.ច.ណ ចុះថ្ងៃទី16 ខែកុម្ភៈឆ្នាំ2018 ស្តីពី "ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអឹមភែរមិន" សម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។ ឥណទាន និងបុរេប្រទានត្រូវបានបែងចែកជាប្រាំថ្នាក់ ហើយត្រូវកត់ត្រាសំវិធានធនអប្បបរមាអាស្រ័យទៅតាមចំណាត់ថ្នាក់របស់វា ដោយមិនគិតដល់ទ្រព្យសកម្មដែលត្រូវបានដាក់ជាទ្រព្យធានា (លើកលែងតែសាច់ប្រាក់)។ ក្រុមប្រឹក្សាភិបាលជឿជាក់ថាអាយុកាលឥណទាន (តាមចំនួនថ្ងៃផុតកំណត់) ដែលជាមូលដ្ឋានកំណត់ចំណាត់ថ្នាក់ឥណទានគឺមានភាពសមស្រប ដើម្បីកំណត់ភាពគ្រប់គ្រាន់នៃការខាតបង់បណ្តាលមកពីការថយចុះតម្លៃនៃបំណុលហិរញ្ញវត្ថុ ដើម្បីឱ្យស្របតាមប្រកាសនេះ។

#### (ខ) ពន្ធ

ពន្ធត្រូវបានគណនាតាមមូលដ្ឋានបំណកស្រាយពន្ធបច្ចុប្បន្ននៃបទប្បញ្ញត្តិពន្ធដារ ដែលបានអនុម័តរួចជាស្ថាពរនាកាលបរិច្ឆេទរបាយការណ៍។ គណៈគ្រប់គ្រងវាយតម្លៃអំពីស្ថានភាពដែលបានប្រកាសពន្ធ ជាមួយនឹងស្ថានភាពនៃបទប្បញ្ញត្តិពន្ធដារ។ ធនាគារកត់ត្រាសំវិធានធនទៅតាមភាពសមស្រប អាស្រ័យទៅតាមមូលដ្ឋាននៃចំនួនប្រាក់ពន្ធ ដែលធនាគាររំពឹងថាត្រូវបង់ជូនអាជ្ញាធរពន្ធដារ។

ទោះបីជាយ៉ាងណាក៏ដោយ បទប្បញ្ញត្តិពន្ធទាំងនេះមានការប្រែប្រួលពីមួយគ្រាទៅមួយគ្រា ហើយការកំណត់ចុងក្រោយលើចំនួនបំណុលពន្ធ នឹងធ្វើឡើងបន្ទាប់ពីមានការត្រួតពិនិត្យរបស់អាជ្ញាធរពន្ធដារ។ នៅពេលដែលលទ្ធផលពន្ធចុងក្រោយមានភាពខុសគ្នាពីការកត់ត្រាដំបូង ភាពខុសគ្នានេះនឹងធ្វើឱ្យប៉ះពាល់ដល់ចំនួនបំណុលពន្ធ និងសមតុល្យទឹកប្រាក់ ក្នុងការិយបរិច្ឆេទដែលការកំណត់ពន្ធនោះត្រូវបានធ្វើឡើង។

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

### 3. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ (ត)

#### (គ) អត្ថប្រយោជន៍បុគ្គលិករយៈពេលវែងផ្សេងៗ - ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ

តម្លៃបច្ចុប្បន្ននៃការទូទាត់ប្រាក់បំណាច់អតីតភាពការងារ អាស្រ័យទៅលើកត្តាមួយចំនួន ដែលត្រូវបានកំណត់តាមមូលដ្ឋានមួយដែលប្រើការសន្មតមួយចំនួន។ ការសន្មតដែលត្រូវបានអនុវត្តក្នុងការកំណត់តម្លៃចុងក្រោយនៃប្រាក់បំណាច់អតីតភាពការងាររួមមាន អត្រាបម្រែបម្រួលបុគ្គលិក និងអត្រាអប្បហារ។ ការផ្លាស់ប្តូរណាមួយនៃការសន្មតទាំងនេះ នឹងធ្វើឱ្យប៉ះពាល់ដល់តម្លៃយោងនៃកាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ។

### 4. សាច់ប្រាក់ក្នុងដៃ

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សាច់ប្រាក់ក្នុងដៃ: | | | | |
| ប្រាក់ដុល្លារអាមេរិក | 2,497 | 10,033 | 2,032 | 8,203 |
| ប្រាក់រៀល | 23 | 92 | 556 | 2,245 |
| | 2,520 | 10,125 | 2,588 | 10,448 |

### 5. សមតុល្យនៅធនាគារកណ្តាល

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| គណនីចរន្ត | 113,872 | 457,538 | 30,084 | 121,449 |
| ប្រាក់តម្កល់ធានាលើដើមទុន | 937,500 | 3,766,875 | 405,000 | 1,634,985 |
| | 1,051,372 | 4,224,413 | 435,084 | 1,756,434 |

#### (ក) ប្រាក់តម្កល់ធានាលើដើមទុន

អនុលោមតាមប្រកាសលេខ ធ7-00-05ប្រ.ក. ចុះថ្ងៃទី11 ខែមករា ឆ្នាំ2000 ស្តីពី ការផ្តល់អាជ្ញាប័ណ្ណដល់ធនាគារឯកទេស និងប្រកាសលេខ ធ៧-06-208ប្រ.ក ចុះថ្ងៃទី13 ខែកញ្ញា ឆ្នាំ2006 ស្តីពីវិសោធនកម្មចំពោះមាត្រា9 និងមាត្រា13 នៃប្រកាសលេខ ធ7-00-05ប្រ.ក. តម្រូវឱ្យធនាគារឯកទេសរក្សាចំនួនទឹកប្រាក់ស្មើនឹង5% នៃដើមទុនចុះបញ្ជីរបស់ខ្លួននៅក្នុងគណនីអចិន្ត្រៃយ៍មួយនៅធនាគារកណ្តាល។ ប្រាក់តម្កល់នេះនឹងត្រូវបង្វិលឱ្យធនាគារវិញ នៅពេលដែលធនាគារស្ម័គ្រចិត្តបញ្ចប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួនហើយប្រាក់តម្កល់នេះមិនសម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារទេ។

#### (ខ) អត្រាការប្រាក់

អត្រាការប្រាក់ប្រចាំឆ្នាំនៃសមតុល្យនៅធនាគារកណ្តាល មានដូចខាងក្រោម៖

| | 2018 | 2017 |
|---|---|---|
| គណនីចរន្ត | សូន្យ | សូន្យ |
| ប្រាក់តម្កល់ធានាលើដើមទុន | 0.46% | 0.32% |

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## 6. សមតុល្យនៅធនាគារផ្សេងៗ

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សមតុល្យនៅធនាគារក្នុងស្រុក | | | | |
| គណនីចរន្ត (*) | 1,074,748 | 4,318,338 | 525,651 | 2,122,053 |
| គណនីសន្សំ (**) | 3,232 | 12,986 | 20,971 | 84,660 |
| ប្រាក់បញ្ញើមានកាលកំណត់ (***) | 7,000,000 | 28,126,000 | 2,950,000 | 11,909,150 |
| | 8,077,980 | 32,457,324 | 3,496,622 | 14,115,863 |
| ដក: សំវិធានធន | (80,780) | (324,574) | - | - |
| | 7,997,200 | 32,132,750 | 3,496,622 | 14,115,863 |

(*) គណនីចរន្តមិនមានការប្រាក់ទេ

(**) គណនីសន្សំមានការប្រាក់ក្នុងចន្លោះពី 0.2% ទៅ 1.00% ក្នុងមួយឆ្នាំ (2017 ៖ 0.75% ក្នុងមួយឆ្នាំ)

(***) ប្រាក់បញ្ញើមានកាលកំណត់ដែលមានរយៈពេលក្នុងចន្លោះពី 3ខែ ទៅ 6ខែ មានអត្រាការប្រាក់ប្រចាំឆ្នាំដូចខាងក្រោម៖

| | 2018 | 2017 |
|---|---|---|
| ប្រាក់បញ្ញើមានកាលកំណត់ | 3.00% - 4.50% | 1.00% - 3.30% |

## 7. ឥណទាន និងបុរេប្រទានអតិថិជន

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានទូទៅ | 13,938,371 | 56,004,375 | 4,090,766 | 16,514,423 |
| ឥណទានទិញរថយន្ត | 10,769,355 | 43,271,268 | - | - |
| ឥណទានបុគ្គលិក | 542,381 | 2,179,287 | 11,057 | 44,637 |
| ឥណទានផ្តល់ឱ្យភាគីពាក់ព័ន្ធ | 1,900,000 | 7,634,200 | - | - |
| | 27,150,107 | 109,089,130 | 4,101,823 | 16,559,060 |
| សំវិធានធនឥណទានបាត់បង់: | | | | |
| សំវិធានធនទូទៅ | (272,145) | (1,093,479) | (39,964) | (161,335) |
| សំវិធានធនជាក់លាក់ | (18,824) | (75,635) | (96,185) | (388,299) |
| ឥណទាន និងបុរេប្រទានអតិថិជន - សុទ្ធ | 26,859,138 | 107,920,016 | 3,965,674 | 16,009,426 |

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

### 7. ឥណទាន និងបុរេប្រទានអតិថិជន (ត)

#### (ក) សំវិធានធនឥណទានបាត់បង់

បម្រែបម្រួលសំវិធានធនឥណទានបាត់បង់ មានដូចខាងក្រោម៖

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នាដើមឆ្នាំ | 136,149 | 549,634 | 97,544 | 393,785 |
| សំវិធានធនក្នុងឆ្នាំ | 154,820 | 622,067 | 38,605 | 155,849 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (2,587) | - | - |
| នាដំណាច់ឆ្នាំ | 290,969 | 1,169,114 | 136,149 | 549,634 |

#### (ខ) វិភាគតាមចំណាត់ថ្នាក់ឥណទាន

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានធម្មតា ៖ | | | | |
| មានការធានា | 26,982,322 | 108,414,970 | 3,985,377 | 16,088,968 |
| មិនមានការធានា | 43,725 | 175,687 | 11,057 | 44,637 |
| ឥណទានឃ្លាំមើល ៖ | | | | |
| មានការធានា | 35,225 | 141,534 | 9,489 | 38,307 |
| មិនមានការធានា | - | - | - | - |
| ឥណទានក្រោមស្តង់ដារ ៖ | | | | |
| មានការធានា | 88,835 | 356,939 | - | - |
| មិនមានការធានា | - | - | - | - |
| ឥណទានសង្ស័យ ៖ | | | | |
| មានការធានា | - | - | - | - |
| មិនមានការធានា | - | - | - | - |
| ឥណទានបាត់បង់ ៖ | | | | |
| មានការធានា | - | - | 95,900 | 387,148 |
| មិនមានការធានា | - | - | - | - |
| | 27,150,107 | 109,089,130 | 4,101,823 | 16,559,060 |

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

### 7. ឥណទាន និងបុរេប្រទានអតិថិជន (ត)

(គ) វិភាគតាមប្រភេទអាជីវកម្ម

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| លក់ដុំ និងលក់រាយ | 1,766,853 | 7,099,215 | 1,018,091 | 4,110,033 |
| ការជួល | 1,245,926 | 5,006,131 | 1,000,000 | 4,037,000 |
| អគារ និងសំណង់ | 5,003,073 | 20,102,347 | 200,525 | 809,519 |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 131,919 | 530,051 | - | - |
| ឥណទាន | 975,761 | 3,920,608 | 77,211 | 311,701 |
| ផលិតកម្ម | 305,714 | 1,228,359 | 8,998 | 36,325 |
| កសិកម្ម | 354,368 | 1,423,851 | 23,933 | 96,618 |
| គ្រឹះស្ថានហិរញ្ញវត្ថុ | 2,142,913 | 8,610,224 | 83,480 | 337,009 |
| យានយន្ត | 10,434,345 | 41,925,198 | - | - |
| ផ្សេងៗ | 4,789,235 | 19,243,146 | 1,689,585 | 6,820,855 |
| | 27,150,107 | 109,089,130 | 4,101,823 | 16,559,060 |

(ឃ) វិភាគតាមហានិភ័យឥណទាន

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ហានិភ័យធំ (*) | 1,900,000 | 7,634,200 | - | - |
| ហានិភ័យធម្មតា | 25,250,107 | 101,454,930 | 4,101,823 | 16,559,060 |
| | 27,150,107 | 109,089,130 | 4,101,823 | 16,559,060 |

(*) ហានិភ័យធំត្រូវបានឱ្យនិយមន័យដោយធនាគារកណ្តាលថា ជាហានិភ័យឥណទានទូទៅ ចំពោះអត្ថគាហកឯកបុគ្គល ដែលលើសពី 10% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

(ង) វិភាគតាមទំនាក់ទំនង

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ភាគីមិនពាក់ព័ន្ធ | 25,250,107 | 101,454,930 | 4,090,766 | 16,514,423 |
| ភាគីពាក់ព័ន្ធ | 1,900,000 | 7,634,200 | 11,057 | 44,637 |
| | 27,150,107 | 109,089,130 | 4,101,823 | 16,559,060 |

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក

## (អតីត ធនាគារឯកទេស តូម៉ាតូ)

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

### 7. ឥណទាន និងបុរេប្រទានអតិថិជន (ត)

#### (ច) វិភាគតាមកាលកំណត់ឥណទាន

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| មិនលើស 1ឆ្នាំ | 1,798,589 | 7,226,731 | 1,142,862 | 4,613,734 |
| លើស 1ឆ្នាំ ប៉ុន្តែមិនលើស ៣ឆ្នាំ | 7,228,232 | 29,043,036 | 686,922 | 2,773,104 |
| លើស 3ឆ្នាំ ប៉ុន្តែមិនលើស 5ឆ្នាំ | 8,208,493 | 32,981,725 | 1,541,672 | 6,223,730 |
| លើស 5ឆ្នាំឡើងទៅ | 9,914,793 | 39,837,638 | 730,367 | 2,948,492 |
| | 27,150,107 | 109,089,130 | 4,101,823 | 16,559,060 |

#### (ឆ) វិភាគតាមរយៈពេលឥណទាន

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានរយៈពេលខ្លី (មួយឆ្នាំ) | 219,540 | 882,112 | - | - |
| ឥណទានរយៈពេល (លើសពីមួយឆ្នាំ) | 26,930,567 | 108,207,018 | 4,101,823 | 16,559,059 |
| | 27,150,107 | 109,089,130 | 4,101,823 | 16,559,059 |

#### (ជ) អត្រាការប្រាក់

| | 2018 | 2017 |
|---|---|---|
| ឥណទានទូទៅ | 5.00% - 18.00% | 5.00% - 18.00% |
| ឥណទានទិញរថយន្ត | 8.00% - 18.00% | - |
| ឥណទានបុគ្គលិក | 5.00% - 11.00% | 5.00% |
| ឥណទានភាគីពាក់ព័ន្ធ | 9.90% | - |

### 8. ទ្រព្យសកម្មផ្សេងៗ

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| បង្គរការប្រាក់ត្រូវទទួល | 177,151 | 711,793 | 38,920 | 157,120 |
| ចំណាយបង់មុន | 256,116 | 1,029,074 | 26,916 | 108,660 |
| ប្រាក់តម្កល់ | 124,236 | 499,180 | 7,851 | 31,694 |
| ផ្សេងៗ | 30,727 | 123,461 | 5,238 | 21,145 |
| | 588,230 | 2,363,508 | 78,925 | 318,619 |

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

8. ទ្រព្យសកម្មផ្សេងៗ (ត)

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| រយៈពេលវែង | 124,236 | 499,180 | 7,851 | 31,694 |
| រយៈពេលខ្លី | 463,994 | 1,864,328 | 71,074 | 286,925 |
| | 588,230 | 2,363,508 | 78,925 | 318,619 |

## 9. ទ្រព្យសម្បត្តិរឹបអូស

ទ្រព្យសម្បត្តិរឹបអូសរួមមានអចលនទ្រព្យផ្សេងៗ ដែលធនាគារទទួលបានតាមរយៈការរឹបអូសទ្រព្យបញ្ចាំពីអតិថិជនដែលខកខានមិនបានសងឥណទាន និងបុរេប្រទាន និងត្រូវបានគ្រប់គ្រងដោយធនាគារវិញ ជាផ្នែកមួយនៃការទូទាត់សងបំណុល។ ទ្រព្យសកម្មទាំងនេះមិនត្រូវបានធនាគារកាន់កាប់ក្នុងគោលបំណងធ្វើប្រតិបត្តិការអាជីវកម្មទេ ហើយនឹងត្រូវបានលក់ចេញដើម្បីប្រមូលចំនួនទឹកប្រាក់ដែលនៅមិនទាន់ទូទាត់ត្រលប់មកវិញ ក្នុងថិរវេលាអតិបរមា12ខែ ដែលត្រូវបានអនុញ្ញាតដោយប្រកាសរបស់ធនាគារកណ្តាល លេខ ធ7-01-186 ប្រ.ក។

បម្រែបម្រួលទ្រព្យសម្បត្តិរឹបអូស មានដូចខាងក្រោម៖

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នាដើមឆ្នាំ | 1,392,400 | 5,621,119 | 1,697,372 | 6,852,291 |
| បន្ថែម | - | - | 344,561 | 1,390,993 |
| ទូទាត់ | (756,147) | (3,038,199) | (590,249) | (2,382,835) |
| ជម្រះចេញពីបញ្ជី | - | - | (59,284) | (239,330) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (26,455) | - | - |
| នាដំណាច់ឆ្នាំ | 636,253 | 2,556,465 | 1,392,400 | 5,621,119 |

## 10. ការវិនិយោគ

ការវិនិយោគនេះគឺជាការវិនិយោគនៅក្នុង Credit Bureau of Cambodia ("CBC")។ ការវិនិយោគនេះត្រូវបានកត់ត្រាតាមថ្លៃដើមដំបូង និងត្រូវបានរក្សាទុកលើសពី12ខែ។

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## 11. ទ្រព្យសម្បត្តិ និងបរិក្ខារ

| រយៈពេលវែង | ការកែលម្អទ្រព្យជួល ដុល្លារអាមេរិក | បរិក្ខារការិយាល័យ ដុល្លារអាមេរិក | គ្រឿងសង្ហារិម និងបរិក្ខារបំពាក់ ដុល្លារអាមេរិក | បរិក្ខារកុំព្យូទ័រ ដុល្លារអាមេរិក | យានយន្ត ដុល្លារអាមេរិក | ការងារកំពុងដំណើការ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | | |
| គិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2018 | 16,811 | 26,967 | 9,910 | 13,765 | - | - | 67,453 |
| ការទិញ | 13,402 | 1,415 | 2,891 | 38,058 | 130,000 | 835,099 | 1,020,865 |
| ការផ្ទេរ | 819,928 | - | - | - | - | (819,928) | - |
| ការជម្រះចេញពីបញ្ជី/លក់ចេញ | (16,811) | (23,255) | (12,493) | - | - | - | (52,559) |
| គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | 833,330 | 5,127 | 308 | 51,823 | 130,000 | 15,171 | 1,035,759 |
| **រំលស់បង្គរ** | | | | | | | |
| គិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2018 | (3,997) | (20,639) | (5,463) | (8,068) | - | - | (38,167) |
| រំលស់ | (83,543) | (964) | (764) | (11,447) | (18,375) | - | (115,093) |
| ការជម្រះចេញពីបញ្ជី/លក់ចេញ | 4,609 | 18,641 | 6,195 | - | - | - | 29,445 |
| គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | (82,931) | (2,962) | (32) | (19,515) | (18,375) | - | (123,815) |
| **តម្លៃចុះបញ្ជីសុទ្ធ** | 750,399 | 2,165 | 276 | 32,308 | 111,625 | 15,171 | 911,944 |
| **គិតជាពាន់រៀល** | 3,015,103 | 8,699 | 1,109 | 129,814 | 448,509 | 60,957 | 3,664,191 |

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

### 11. ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

| រយៈពេលវែង | ការកែលម្អទ្រព្យជួល ដុល្លារអាមេរិក | បរិក្ខារការិយាល័យ ដុល្លារអាមេរិក | គ្រឿងសង្ហារិម និងបរិក្ខារបំពាក់ ដុល្លារអាមេរិក | បរិក្ខារកុំព្យូទ័រ ដុល្លារអាមេរិក | យានយន្ត ដុល្លារអាមេរិក | ការងារកំពុងដំណើការ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | | |
| គិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2017 | 16,811 | 27,727 | 33,557 | 9,399 | - | - | 87,494 |
| ការទិញ | - | - | 2,748 | 5,543 | - | - | 8,291 |
| ការផ្ទេរ | - | - | - | - | - | - | - |
| ការលក់ចេញ | - | (760) | (26,395) | (1,177) | - | - | (28,332) |
| គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2017 | 16,811 | 26,967 | 9,910 | 13,765 | - | - | 67,453 |
| **រំលស់បង្គរ** | | | | | | | |
| គិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2017 | (2,316) | (18,755) | (31,021) | (6,755) | - | - | (58,847) |
| រំលស់ | (1,681) | (2,209) | (837) | (2,427) | - | - | (7,154) |
| ការលក់ចេញ | - | 325 | 26,395 | 1,114 | - | - | 27,834 |
| គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2017 | (3,997) | (20,639) | (5,463) | (8,068) | - | - | (38,167) |
| **តម្លៃចុះបញ្ជីសុទ្ធ** | 12,814 | 6,328 | 4,447 | 5,697 | - | - | 29,286 |
| **គិតជាពាន់រៀល** | 51,730 | 25,546 | 17,953 | 22,999 | - | - | 118,228 |

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## 12. ទ្រព្យសកម្មអរូបី

| រយៈពេលវែង | កម្មវិធីកុំព្យូទ័រ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|
| **ថ្លៃដើម** | | |
| គិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2018 | 42,393 | 42,393 |
| ការទិញ | 5,600 | 5,600 |
| គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | 47,993 | 47,993 |
| **រំលស់បង្គរ** | | |
| គិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2018 | (27,607) | (27,607) |
| រំលស់ | (4,494) | (4,494) |
| គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | (32,101) | (32,101) |
| **តម្លៃចុះបញ្ជីសុទ្ធ** | 15,892 | 15,892 |
| **គិតជាពាន់រៀល** | 63,854 | 63,854 |
| **ថ្លៃដើម** | | |
| គិតត្រឹមថ្ងៃទី01ខែមករា ឆ្នាំ2017 | 46,058 | 46,058 |
| ការទិញ | 1,539 | 1,539 |
| ការលក់ចេញ | (5,204) | (5,204) |
| **គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2017** | 42,393 | 42,393 |
| **រំលស់បង្គរ** | | |
| គិតត្រឹមថ្ងៃទី01 ខែមករា ឆ្នាំ2017 | (26,144) | (26,144) |
| រំលស់ | (4,569) | (4,569) |
| ការលក់ចេញ | 3,106 | 3,106 |
| គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2017 | (27,607) | (27,607) |
| **តម្លៃចុះបញ្ជីសុទ្ធ** | 14,786 | 14,786 |
| **គិតជាពាន់រៀល** | 59,691 | 59,691 |

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## 13. បំណុលផ្សេងៗ

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ទឹកប្រាក់ជំពាក់ភាគទុនិក (កំណត់សម្គាល់25) | 322,984 | 1,297,750 | - | - |
| បង្គរប្រាក់រង្វាន់ | - | - | 22,794 | 92,019 |
| បង្គរការប្រាក់ត្រូវបង់ | 34,837 | 139,975 | - | - |
| ពន្ធត្រូវបង់ផ្សេងៗ | 98,877 | 397,288 | 14,728 | 59,457 |
| កាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ | 15,144 | 60,849 | - | - |
| បុរេប្រទានពីអតិថិជន | 85,336 | 342,880 | 2,738 | 11,053 |
| ចំណូលមិនទាន់រកបាន | - | - | 13,597 | 54,891 |
| ផ្សេងៗ | 103,109 | 414,291 | 149,243 | 602,495 |
| | 660,287 | 2,653,033 | 203,100 | 819,915 |

| | | | | |
|---|---|---|---|---|
| រយៈពេលវែង | 15,144 | 60,849 | - | - |
| រយៈពេលខ្លី | 645,143 | 2,592,184 | 203,100 | 819,915 |
| | 660,287 | 2,653,033 | 203,100 | 819,915 |

## 14. ប្រាក់កម្ចី

### ក) វិភាគតាមទំនាក់ទំនង

| | 2018 | |
|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល |
| **ភាគីមិនពាក់ព័ន្ធ:** | | |
| ធនាគារ The Korea Development Bank | 15,000,000 | 60,270,000 |
| **ភាគីពាក់ព័ន្ធ:** | | |
| ធនាគារ Kookmin Bank Plc. (កំណត់សម្គាល់ 25) | 3,000,000 | 12,054,000 |
| ប្រាក់កម្ចីសរុប | 18,000,000 | 72,324,000 |

### (ខ) អត្រាការប្រាក់

| | 2018 |
|---|---|
| អត្រាការប្រាក់ប្រចាំឆ្នាំ | Libor 3 ខែ + 1.60% និង 4.15% ក្នុងមួយឆ្នាំ |

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## 14. ប្រាក់កម្ចី (ត)

**គ) វិភាគតាមកាលកំណត់**

| | 2018 | |
|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល |
| រយៈពេលវែង | | |
| ផុតកំណត់ក្នុងរយៈពេលពី 1ឆ្នាំ ទៅ 2ឆ្នាំ | 18,000,000 | 72,324,000 |
| | 18,000,000 | 72,324,000 |

ប្រាក់កម្ចីត្រូវបានធានាដោយលិខិតធានារបស់ភាគទុនិក។

## 15. ដើមទុន

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សមតុល្យដើមគ្រា | 8,100,000 | 32,699,700 | 8,100,000 | 32,699,700 |
| ដើមទុនបានបង់ក្នុងអំឡុងឆ្នាំ: | | | | |
| ការដាក់ដើមទុនបន្ថែម | 10,650,000 | 42,791,700 | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (153,900) | - | - |
| សមតុល្យចុងគ្រា | 18,750,000 | 75,337,500 | 8,100,000 | 32,699,700 |

ក្នុងអំឡុងឆ្នាំ ភាគទុនិកបានអនុម័ត និងបោះផ្សាយភាគហ៊ុនបន្ថែមចំនួន 10,650,000 លានដុល្លារអាមេរិក (10.65 លានភាគហ៊ុន) ដែលមានតម្លៃចារិក 1ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន។ ដើមទុនបន្ថែមត្រូវបានបង់រួចក្នុងអំឡុងឆ្នាំ។ ធនាគារកណ្តាលបានអនុម័តដើមទុនបានបង់នេះ នៅថ្ងៃទី23 ខែមីនា ឆ្នាំ2018។ អនុស្សារណៈ និងលក្ខន្តិកៈរបស់ធនាគារ ត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី06 ខែកក្កដា ឆ្នាំ2018។

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 អនុបាតនៃការកាន់កាប់ភាគហ៊ុនថ្មីរបស់ភាគទុនិកនីមួយៗ មានដូចខាងក្រោម៖

| ភាគទុនិក | ចំនួនភាគហ៊ុន | អនុបាតភាគហ៊ុន |
|---|---|---|
| KB Kookmin Card Co., Ltd. | 16,875,000 | 90% |
| Indochina Bank Ltd. | 1,875,000 | 10% |

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## 16. ចំណូលការប្រាក់

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ពី: | | | | |
| ឥណទាន និងបុរេប្រទានអតិថិជន | 1,303,810 | 5,238,709 | 501,333 | 2,023,881 |
| សមតុល្យនៅធនាគារកណ្តាល | 4,552 | 18,290 | 1,826 | 7,372 |
| សមតុល្យនៅធនាគារផ្សេងៗ | 66,040 | 265,348 | 95,414 | 385,186 |
| | 1,374,402 | 5,522,347 | 598,573 | 2,416,439 |

## 17. ចំណូលសោហ៊ុយ និងកម្រៃជើងសា

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| កម្រៃដំណើរការឥណទាន | 280,650 | 1,127,652 | 42,039 | 169,711 |
| កម្រៃផាកពិន័យចំពោះការយឺតយ៉ាវក្នុងការ សងឥណទាន និងបុរេប្រទាន | 3,170 | 12,737 | 7,894 | 31,869 |
| | 283,820 | 1,140,389 | 49,933 | 201,580 |

## 18. ចំណូលផ្សេងៗ

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលភាគលាភពី CBC | 4,874 | 19,584 | 4,950 | 19,983 |
| ចំណូលផ្សេងៗ | 60,179 | 241,799 | 53,681 | 216,710 |
| | 65,053 | 261,383 | 58,631 | 236,693 |

## 19. ចំណាយបុគ្គលិក

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់បៀវត្សរ៍ | 850,644 | 3,417,888 | 162,871 | 657,510 |
| ប្រាក់រង្វាន់ | 107,013 | 429,978 | 50,575 | 204,171 |
| កាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ | 15,144 | 60,849 | - | - |
| ផ្សេងៗ | 35,900 | 144,246 | 94,446 | 381,279 |
| | 1,008,701 | 4,052,961 | 307,892 | 1,242,960 |

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក

## ( អតីត ធនាគារឯកទេស តូម៉ាតូ )

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## 20. ចំណាយរដ្ឋបាល និងចំណាយប្រតិបត្តិការ

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណាយថ្លៃជួល | 153,766 | 617,832 | 84,052 | 339,318 |
| កម្រៃផ្នែកច្បាប់ និងវិជ្ជាជីវៈ | 146,742 | 589,609 | 111,492 | 450,093 |
| ទំនាក់ទំនងសាធារណៈ | 91,150 | 366,241 | 13,494 | 54,475 |
| ចំណាយពន្ធផ្សេងៗ | 60,509 | 243,125 | 58,742 | 237,142 |
| ចំណាយផ្សាយពាណិជ្ជកម្ម | 58,281 | 234,173 | 5,580 | 22,526 |
| សម្ភារការិយាល័យ | 48,976 | 196,786 | 23,173 | 93,549 |
| ទឹក-ភ្លើង | 27,145 | 109,069 | 16,663 | 67,269 |
| ការកំសាន្ត | 27,076 | 108,791 | 22,093 | 89,189 |
| ពន្ធអប្បបរមា 1% | 17,232 | 69,238 | 10,572 | 42,679 |
| ការធ្វើដំណើរ | 14,164 | 56,911 | 28,731 | 115,987 |
| កម្រៃសមាជិកភាព | 8,337 | 33,498 | 6,908 | 27,888 |
| សោហ៊ុយអាជ្ញាប័ណ្ណ | 4,200 | 16,876 | 715 | 2,886 |
| សន្តិសុខ | 3,840 | 15,429 | 7,680 | 31,004 |
| ផ្សេងៗ | 83,359 | 334,936 | 86,266 | 348,257 |
| | 744,777 | 2,992,514 | 476,161 | 1,922,262 |

## 21. ចំណាយពន្ធលើប្រាក់ចំណូល

### ( ក ) ចំណាយពន្ធលើប្រាក់ចំណូល

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណាយពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ | - | - | - | - |
| ពន្ធពន្យារ | - | - | - | - |
| ចំណាយពន្ធលើប្រាក់ចំណូល | - | - | - | - |

### ( ខ ) ការផ្ទៀងផ្ទាត់រវាងចំណាយពន្ធលើប្រាក់ចំណូល និងចំណេញតាមគណនេយ្យ

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ខាតមុនបង់ពន្ធលើប្រាក់ចំណូល | (460,003) | (1,848,293) | (116,672) | (471,005) |
| ពន្ធគណនាតាមអត្រា 20% | (92,001) | (369,658) | (23,334) | (94,201) |
| ផលប៉ះពាល់ពន្ធលើខ្ទង់ដែលបានផ្ទៀងផ្ទាត់: | | | | |
| ចំណាយមិនអាចកាត់កងបាន | 23,833 | 95,760 | 31,332 | 126,487 |
| ពន្ធពន្យារទ្រព្យសកម្មមិនទាន់បានទទួលស្គាល់ | 64,569 | 259,439 | (60,840) | (245,612) |
| | (3,599) | (14,459) | (52,842) | (213,326) |
| ចំណាយពន្ធលើប្រាក់ចំណូល | - | - | - | - |

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## 21. ចំណាយពន្ធលើប្រាក់ចំណូល (ត)

យោងតាមច្បាប់ស្តីពីសារពើពន្ធ ធនាគារមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូលតាមចំនួនមួយណាដែលខ្ពស់ជាងរវាង 20%នៃប្រាក់ចំណេញជាប់ពន្ធ ឬពន្ធអប្បបរមា 1% នៃផលរបរ។ ធនាគារត្រូវបង់ពន្ធអប្បបរមា 1% ដូចបានលាតត្រដាងក្នុងកំណត់សម្គាល់ 20។

### (គ) ពន្ធពន្យារ

គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ធនាគារមិនបានទទួលស្គាល់ពន្ធពន្យារទ្រព្យសកម្ម ដែលមានទឹកប្រាក់ចំនួន 64,569 ដុល្លារអាមេរិកទេ ដោយសារធនាគារមិនមានភាពប្រាកដថានឹងមានប្រាក់ចំណេញជាប់ពន្ធ ដែលអាចបង្កើតឱ្យមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតបាន។

## 22. លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ខាតមុនបង់ពន្ធលើប្រាក់ចំណូល | (460,003) | (1,848,293) | (127,244) | (513,685) |
| និយ័តកម្ម: | | | | |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | 115,093 | 462,444 | 7,154 | 28,881 |
| រំលស់ទ្រព្យសកម្មអរូបី | 4,494 | 18,057 | 4,568 | 18,441 |
| អចលនទ្រព្យដែលបានជម្រះចេញពីបញ្ជី/លក់ចេញ | 21,994 | 88,372 | 2,597 | 10,484 |
| សំវិធានធនឥណទានបាត់បង់ | 154,820 | 622,067 | 38,605 | 155,848 |
| សំវិធានធនសមតុល្យនៅធនាគារផ្សេងៗ | 80,780 | 324,574 | - | - |
| ចំណាយការប្រាក់សុទ្ធ | (1,374,402) | (5,522,347) | (598,573) | (2,416,439) |
| ចំណូលការប្រាក់សុទ្ធ | 74,613 | 299,795 | - | - |
| | (1,382,611) | (5,555,331) | (672,893) | (2,716,470) |
| បម្រែបម្រួលដើមទុនបង្វិល | | | | |
| ឥណទាន និងបុរេប្រទានអតិថិជន | (23,048,284) | (92,608,005) | 808,905 | 3,265,549 |
| សមតុល្យនៅធនាគារផ្សេងៗ | (4,650,000) | (18,683,700) | (1,200,000) | (4,844,400) |
| ទ្រព្យសកម្មផ្សេងៗ | (371,074) | (1,490,975) | (1,280) | (5,167) |
| ការវិនិយោគ | - | - | 294 | 1,187 |
| ទ្រព្យសម្បត្តិរឹបអូស | 756,147 | 3,038,199 | 304,972 | 1,231,172 |
| បំណុលផ្សេងៗ | 422,351 | 1,697,006 | (56,996) | (230,091) |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងប្រតិបត្តិការ | (28,273,471) | (113,602,806) | (816,998) | (3,298,220) |

# ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
## (អតីត ធនាគារឯកទេស តូម៉ាតូ)
## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី31 ខែធ្នូ ឆ្នាំ2018

## 23. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

ក្នុងការរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូល មាន៖

| | 2018 | | 2017 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សាច់ប្រាក់ក្នុងដៃ | 2,520 | 10,125 | 2,588 | 10,448 |
| សមតុល្យនៅធនាគារកណ្តាល: | | | | |
| គណនីចរន្ត | 113,872 | 457,538 | 30,084 | 121,449 |
| សមតុល្យនៅធនាគារផ្សេងៗ: | | | | |
| គណនីចរន្ត | 1,074,749 | 4,318,341 | 525,651 | 2,122,053 |
| គណនីសន្សំ | 3,232 | 12,986 | 20,971 | 84,660 |
| ប្រាក់បញ្ញើមានកាលកំណត់ | 1,000,000 | 4,018,000 | 1,600,000 | 6,459,200 |
| | 2,194,373 | 8,816,990 | 2,179,294 | 8,797,810 |

## 24. កិច្ចសន្យាផ្សេងៗ

